៥២

# ខុទ្ទកនិកាយគាថាធម្មបទ

## វគ្គទី ៩

## ឈ្មោះសហស្សវគ្គ

ប្រែ និងរៀបរៀងដោយ ភិក្ខុ សុវណ្ណថេរោ **លឹម ឆន់**

ខេត្តបាត់ដំបង ព.ស ២៥៥០

# ខុទ្ទកនិកាយគាថាធម្មបទ

## វគ្គទី ៨

## ឈ្មោះសហស្សវគ្គ

ប្រែ និងរៀបរៀងដោយ ភិក្ខុ សុវណ្ណថេរោ **លឹម ធន់**

ខេត្តបាត់ដំបង ព.ស ២៥៥០

# ខុទ្ទកនិកាយគាថាធម្មបទ

## បាបវគ្គ វគ្គទី ៩

១ អភិត្ថរេថ កល្យាណេ បាបា ចិត្តំ និវារយេ
ទន្ធំ ហិករតោ បុញ្ញំ បាបស្មឹ រមតី មនោ ។

បុគ្គល គួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរ
ឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើ
បុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ។

២ បាបញ្ចេ បុរិសោ កយិរា ន នំ កយិរា បុនប្បុនំ
ន តម្ហិ ឆន្ទំ កយិរាថ ទុក្ខោ បាបស្ស ឧច្ចយោ ។

បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយៗ ឡើយ កុំ
កុំគប្បីធ្វើសេចក្តីពេញចិត្តក្នុងបាបនោះ (ព្រោះថា)
ការសន្សំបាប តែងនាំសេចក្តីទុក្ខមកឲ្យ ។

៣ បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ
តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ។

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឲ្យរឿយៗ គួរ
ធ្វើសេចក្តីពេញចិត្តក្នុងបុណ្យនោះ ( ព្រោះថា ) ការ

សន្សំបុណ្យ តែងនាំសេចក្ដីសុខមកឲ្យ ។

៤ បាបោបិ បស្សតី ភទ្រំ  យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ  អថ (បាបោ) បាបានិ បស្សតិ
ភទ្រោបិ បស្សតី បាបំ  យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតី ភទ្រំ  អថ (ភទ្រោ) ភទ្រានិ បស្សតិ ។

បាបមិនទាន់ឲ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែសេចក្ដីចំរើនត្រឹមណោះ លុះកាលណាបាបឲ្យផល មនុស្សបាប ទើបឃើញបាបក្នុងកាលនោះ ។

អំពើល្អមិនទាន់ឲ្យផលត្រឹមណា មនុស្សល្អនៅឃើញតែបាបត្រឹមណោះ លុះកាលណា អំពើល្អឲ្យផល មនុស្សល្អ ទើបឃើញល្អក្នុងកាលនោះ ។

៥ មាវមញ្ញេថ បាបស្ស  ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន  ឧទកុម្ភោបិ បូរតិ
បូរតិ ពាលោ បាបស្ស  ថោកំ ថោកំបិ អាចិនំ ។

បុគ្គលមិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឲ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹករមែងពេញបានដោយដំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា បុគ្គលពាល កាលសន្សំបាប សូម្បីបន្តិចម្ដងៗគង់ពេញបានដោយបាប យ៉ាងនោះដែរ ។

៦ មាវមញ្ញេថ បុញ្ញស្ស       ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន       ឧទកុម្ភោបិ បូរតិ
បូរតិ ធីរោ បុញ្ញស្ស       ថោកំ ថោកំបិ អាចិនំ ។

បុគ្គលមិនគួរមើលងាយបុណ្យថា មានប្រមាណតិច នឹងមិនឲ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹករមែងពេញបានដោយដំណក់ទឹក ដែលធ្លាក់ចុះ យ៉ាងណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្តងៗ គង់ពេញបានដោយបុណ្យយ៉ាងនោះ ។

៧ វាណិជោវ ភយំ មគ្គំ       អប្បសត្ថោ មហទ្ធនោ
វិសំ ជីវិតុកាមោវ       បាបានិ បរិវជ្ជយេ ។

បុគ្គលគួរចៀសវាងបាបទាំងឡាយ ឲ្យដូចពាណិជដែលមានទ្រព្យច្រើន តែមានគ្នាតិចចៀសវាងផ្លូវគួរខ្លាច ឬដូចជាបុរសប្រាថ្នារស់ចៀសវាងថ្នាំពិសដូច្នោះដែរ ។

៨ បាណិម្ហិ ចេ វណោ នាស្ស       ហរេយ្យ បាណិនា វិសំ
នាព្វណំ វិសមន្វេតិ       នត្ថិ បាបំ អកុព្វតោ ។

បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីនាំយកថ្នាំពិសដោយបាតដៃ ថ្នាំពិសតែងមិនជ្រាបចូលទៅកាន់បាតដៃដែលគ្មានដំបៅ យ៉ាងណា បាប

រមែងមិនមាន ដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះដែរ ។

៩ យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ
សុទ្ធស្ស បោសស្ស អនង្គណស្ស
តមេវ ពាលំ បច្ចេតិ បាបំ
សុខុមោ រជោ បដិវាតំវ ខិត្តោ ។

បុគ្គលណាប្រទូស្ត ចំពោះអ្នកមិនប្រទូស្តតប ជាសត្វស្អាត មិនមានកិលេស ដូចជាទីទួល បាប រមែងត្រឡប់មករកបុគ្គលពាលនោះវិញ ដូចធូលីល្អិត ដែលបុគ្គលបាចទៅកាន់ទីច្រាស់ខ្យល់ ។

១០ គព្ភមេកេ ឧប្បជ្ជន្តិ និរយំ បាបកម្មិនោ
សគ្គំ សុគតិនោ យន្តិ បរិនិព្វន្តិ អនាសវា ។

ជនពួកខ្លះ កើតក្នុងគភ៌មនុស្ស ពួកអ្នកធ្វើអំពើអាក្រក់ ទៅកាន់នរក ពួកអ្នកមានគតិល្អ ទៅកាន់ស្ថានសួគ៌ ពួកអ្នកមិនមានអាសវៈ បរិនិព្វាន ។

១១ ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្វតានំ វិវរំ បវិស្ស
ន វិជ្ជតេ សោ ជគតិប្បទេសោ
យត្រដ្ឋិតោ មុច្ចេយ្យ បាបកម្មា ។

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅ

ពួជ៏អាកាស ក្នុងកណ្តាលសមុទ្ទ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលស្ថិតនៅហើយ គប្បីរួចចាកបាបកម្មបាននោះ មិនដែលមានឡើយ ។

**១២ ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**
**ន បព្វតានំ វិវរំ បវិស្ស**
**ន វិជ្ជតេ សោ ជគតិប្បទេសោ**
**យត្រដ្ឋិតំ នប្បសហេយ្យ មច្ចុ ។**

បុគ្គលទៅពួជ៏អាកាស ក្នុងកណ្តាលសមុទ្ទ កាន់ចន្លោះនៃភ្នំទាំងឡាយ ក៏មិនរួចចាកសេចក្តីស្លាប់បាន ព្រោះប្រទេសលើផែនដី ដែលបុគ្គលស្ថិតនៅហើយ សេចក្តីស្លាប់គ្របសង្កត់មិនបាននោះ មិនមានឡើយ ។

# ៩ បាបវគ្គវណ្ណនា

## ១ រឿងព្រាហ្មណ៍ឈ្មោះចូឡេកសាដក

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ឈ្មោះចូឡេកសាដក បានត្រាស់ព្រះធម្មទេសនានេះថា “**អភិត្ថរេថ កល្យាណេ**” ជាដើម ។

### ព្រាហ្មណ៍និងព្រាហ្មណីផ្លាស់វេនគ្នាទៅស្តាប់ធម៌

បានឮថា ក្នុងកាលនៃព្រះវិបស្សីទសពល មានព្រាហ្មណ៍ម្នាក់ឈ្មោះមហាឯកសាដក ។ ប៉ុន្តែក្នុងកាលនៃព្រះសម្មាសម្ពុទ្ធនៃយើងនេះ គាត់មានឈ្មោះថា ចូឡេកសាដក មានប្រក្រតីនៅក្នុងក្រុងសាវត្ថី ។ ក៏សំពត់សាដកសំរាប់ស្លៀករបស់ព្រាហ្មណ៍នោះ មានតែមួយផ្ទាំង, សូម្បីនាងព្រាហ្មណីក៏មានតែមួយផ្ទាំងដែរ, ទាំងពីរនាក់ប្តីប្រពន្ធមានសំពត់

ដណ្ដប់តែមួយផ្ទាំងប៉ុណ្ណោះ ។ ថ្ងៃមួយ កាលគេប្រកាសការស្ដាប់ធម៌ក្នុងវិហារ ព្រាហ្មណ៍បានពោលនឹងព្រាហ្មណី "ម្នាលនាងដ៏ចម្រើន គេប្រកាសការស្ដាប់ធម៌, នាងនឹងទៅស្ដាប់ព្រះធម៌ក្នុងវេលាថ្ងៃឬក៏វេលាយប់ ? ព្រោះយើងទាំងពីរនាក់មិនអាចនឹងទៅព្រមគ្នាបានទេ ត្បិតយើងមានសំពត់ដណ្ដប់តែមួយផ្ទាំង" ។ ព្រាហ្មណីតបថា "នាយ ខ្ញុំនឹងទៅក្នុងវេលាថ្ងៃ" លុះពោលដូច្នេះហើយ ក៏ដណ្ដប់សំពត់សាដកនោះធ្វើដំណើរទៅកាន់កន្លែងស្ដាប់ព្រះធម៌ ។

## ព្រាហ្មណ៍គិតបូជាធម៌ដោយសំពត់សាដក

ព្រាហ្មណ៍នៅចាំផ្ទះពេញមួយថ្ងៃ លុះដល់វេលាយប់ទើបបានទៅអង្គុយស្ដាប់ធម៌ខាងមុខព្រះភក្ត្រព្រះសាស្ដា ។ គ្រានោះ បីតិ ៥ យ៉ាងបានកើតឡើងផ្សព្វផ្សាយទូទៅពេញសរីរៈរបស់ព្រាហ្មណ៍នោះ ធ្វើឲ្យគាត់មានប្រាថ្នាចង់បូជាសំពត់ដណ្ដប់ចំពោះព្រះសាស្ដា ពេលនោះសេចក្ដីកំណាញ់ក៏បានកើតឡើងធ្វើឲ្យគាត់គិតថា "ប្រសិនបើយើងនឹងថ្វាយសំពត់សាដកនេះចំពោះព្រះសាស្ដា, ករិយារបស់យើងនឹងមិនមានសំពត់ដណ្ដប់ សូម្បីយើងក៏មិនមានដែរ ។ ខណៈ

នោះ ចិត្តប្រកបដោយសេចក្ដីកំណាញ់ ១០០០ ដួងក៏បាន កើតឡើងដល់គាត់, ចិត្តប្រកបដោយសទ្ធា ១ ដួងក៏បាន កើតឡើងទៀត, ចិត្តប្រកបដោយសេចក្ដីកំណាញ់ពាន់ដួង ក៏បានកើតឡើងគ្របសង្កត់ចិត្តដែលប្រកបដោយសទ្ធានោះ ទៀតៗ សេចក្ដីកំណាញ់ដ៏មានកំលាំងរបស់គាត់ក៏បានកើត ឡើងរាំងចិត្តដែលប្រកបដោយសទ្ធាមិនឲ្យកើតឡើង ដូច ជាចាប់ចងទុកយ៉ាងមាំដូច្នេះ ។

## ឈ្នះមច្ឆេរចិត្តដោយសទ្ធាចិត្ត

កាលគាត់កំពុងតែគិតថា "នឹងថ្វាយឬមិនថ្វាយ" ដូច្នេះ នោះ បឋមយាមនៃរាត្រីក៏បានកន្លងទៅ ។ សូម្បីមជ្ឈិម យាមចូលមកដល់ ក៏គាត់នៅតែមិនអាចថ្វាយសំពត់សាដក ចំពោះព្រះសាស្ដាបានទៀត ។ លុះដល់បច្ឆិមយាម គាត់ ក៏គិតថា កាលយើងច្បាំងជាមួយនិងមច្ឆរយចិត្តដោយសទ្ធា ចិត្តនោះឯង យាមពីរក៏បានកន្លងផុតទៅហើយ, មច្ឆេរយចិត្ត របស់យើងនេះកាលចំរើនឡើងហើយ នឹងមិនឲ្យយើងងើប សីសៈឡើងអំពីអបាយ ៤បាន, ដូច្នេះ យើងត្រូវតែថ្វាយ សំពត់សាដកនេះចំពោះព្រះសាស្ដាឲ្យខានតែបាន ។ គាត់

គ្របសង្កត់សេចក្ដីកំណាញ់ទាំង ១០០០ ដួងបានហើយ ធ្វើសទ្ធាចិត្តឲ្យជាបុរេចារិក ( ដឹកមុខ ) ហើយកាន់យកសំពត់សាដកទៅដំលក់ទៀបបាទមូលរបស់ព្រះសាស្ដាហើយ បានស្រែកដោយមានសំឡេងខ្លាំងៗ ៣ ដងថា“យើងឈ្នះហើយ យើងឈ្នះហើយ ជាដើម” ។

# ទានរបស់ព្រាហ្មណ៍ឲ្យផលទាន់ភ្នែក

ព្រះបាទបសេនទិកោសល កំពុងតែទ្រង់ស្ដាប់ព្រះធម៌ ទ្រង់បានព្រះសណ្ដាប់នូវសំឡេងនោះហើយ ត្រាស់ថា ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយចូរសួរ ព្រាហ្មណ៍នោះមើល, តើគេបានឈ្នះអ្វី ?

ព្រាហ្មណ៍នោះ ត្រូវពួករាជបុរសសួរ ក៏បានឆ្លើយប្រាប់នូវសេចក្ដីនោះចំពោះពួករាជបុរស ។ ព្រះរាជាទ្រង់សណ្ដាប់នូវសេចក្ដីនោះហើយ ក៏ទ្រង់ព្រះតំរិះថា ព្រាហ្មណ៍នេះបានធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ យើងនឹងធ្វើការសង្គ្រោះគេ លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ទ្រង់បញ្ជាឲ្យព្រះរាជទានសំពត់សាដកមួយគូដល់ព្រាហ្មណ៍នោះ ។

ព្រាហ្មណ៍បានថ្វាយសំពត់មួយគូនោះចំពោះព្រះតថា-

គតទៀត ព្រះរាជាក៏ត្រាស់បញ្ជាឲ្យព្រះរាជទានជាទ្វិគុណទៀត គឺ ២ គូ ៤ គូ ៨ គូ ១៦ គូ ។ ព្រាហ្មណ៍ក៏បានថ្វាយសំពត់ ទាំងនោះចំពោះព្រះតថាគតអស់ទៀត ។ តមក ព្រះរាជាត្រាស់បញ្ជាឲ្យព្រះរាជទានសំពត់ ៣២ គូដល់គាត់ ។

ដើម្បីនឹងដោះស្រាយវាទៈថា "ព្រាហ្មណ៍មិនកាន់យកសំពត់ដែលព្រះរាជាបានព្រះរាជទានដើម្បីខ្លួនទេ លះបង់សំពត់ដែលបានហើយៗអស់ ទើបកាន់យកសំពត់ ២ គូអំពើសំពត់ ៣២ គូនោះ ដើម្បីខ្លួន ១ គូ ដើម្បីនាងព្រាហ្មណី ១ គូ បានថ្វាយសំពត់ ៣០ គូចំពោះព្រះតថាគតទៀត ។ ចំណែកព្រះរាជា កាលព្រាហ្មណ៍នោះថ្វាយដល់ ៧ ដងទ្រង់មានព្រះរាជបំណងចង់ព្រះរាជទានទៀត ។ ព្រាហ្មណ៍ឈ្មោះមហាឯកសាដក ក្នុងកាលមុន បានកាន់យកសំពត់សាដក ២ គូ អំពីសំពត់សាដក ៦៤ គូ ។ ចំណែកព្រាហ្មណ៍ឈ្មោះចូឡេកសាដកនេះ បានកាន់យកសំពត់សាដក ២ គូ ក្នុងវេលាដែលខ្លួនបានសំពត់សាដក ៣២ គូ ។

ព្រះរាជាទ្រង់បង្គាប់ពួករាជបុរសថា នែអ្នកទាំងឡាយ

ព្រាហ្មណ៍នេះបានធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ អ្នកទាំងឡាយ គប្បីឲ្យគេនាំយកសំពត់កម្ពល ២ ផ្ទាំងខាងក្នុងវាំងរបស់ យើងមក ។ ពួករាជបុរសក៏បានធ្វើតាមព្រះរាជបញ្ជា ។ ព្រះរាជាបញ្ជាឲ្យព្រះរាជទានសំពត់កម្ពល ២ ផ្ទាំងដែលមានតំលៃ ១ សែនដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍គិតថា សំពត់កម្ពលទាំងនេះ មិនសមគួរប៉ះពាល់ដល់សរីរៈរបស់យើងទេ, សំពត់ទាំងនេះសមគួរតែព្រះពុទ្ធសាសនាប៉ុណ្ណោះ ទើបយកសំពត់កម្ពល ១ ផ្ទាំងទៅចងធ្វើជាពិតានខាងលើគ្រែផ្ទំរបស់ព្រះសាស្តាខាងក្នុងព្រះគន្ធកុដិ, យក១ផ្ទាំងទៀតទៅចងធ្វើជាពិតានខាងលើទីសំរាប់ធ្វើភត្តកិច្ចរបស់ភិក្ខុទាំងឡាយដែលឆាន់ជាប្រចាំក្នុងផ្ទះរបស់ខ្លួន ។ ក្នុងវេលារសៀល ព្រះរាជាស្តេចយាងទៅកាន់សំណាក់របស់ព្រះសាស្តា ទ្រង់ចាំសំពត់កម្ពលបាន ក៏ទូលសួរព្រះសាស្តាថា “បពិត្រព្រះអង្គដ៏ចម្រើន នរណាបូជាសំពត់កម្ពលនេះចំពោះព្រះអង្គ ?” កាលព្រះសាស្តាត្រាស់តបថា “ព្រាហ្មណ៍ឈ្មោះឯកសាដក” ដូច្នេះហើយ ទ្រង់ព្រះតំរិះថា “ព្រាហ្មណ៍ជ្រះថ្លាក្នុងឋានៈដែលយើងជ្រះថ្លាដែរ” ទ្រង់បញ្ជា

ឲ្យព្រះរាជទានពួក ៤ នៃវត្ថុគ្រប់យ៉ាង រហូតដល់រយនៃវត្ថុទាំងឡាយ ទ្រង់ធ្វើវត្ថុមួយមុខ១៧៤ ដល់ព្រាហ្មណ៍នោះយ៉ាងនេះគឺ ដំរី ៤ សេះ ៤ កហាបណៈ ៤០០០ ស្ត្រី ៤ បុរស ៤ ស្រុកសួយ ៤ តំបន់ ។

## ប្រញាប់ធ្វើកុសលមានផលល្អជាងធ្វើយឺត

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាសាលាថា ឱ ! កម្មរបស់ព្រាហ្មណ៍ឈ្មោះចូឡេកសាដក គួរឲ្យអស្ចារ្យណាស់, តែមួយរំពេចប៉ុណ្ណោះ គាត់បាននូវប្រមាណ ៤ នៃវត្ថុទាំងពួង, កម្មជាកុសលដែលព្រាហ្មណ៍ធ្វើហើយក្នុងស្រែបុណ្យដ៏ប្រសើរ ឲ្យផលក្នុងថ្ងៃនេះឯង ។

ព្រះសាស្តាស្តេចយាងមកហើយត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយសន្ទនាគ្នាអំពីកថាអ្វី ?" កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនពួក, ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ប្រសិនបើឯកសាដកនេះ ថ្វាយសំពត់សាដកចំពោះតថាគតក្នុងបឋមយាម គាត់នឹងបាននូវប្រមាណ១៦នៃវត្ថុទាំងពួង, បើគាត់បានថ្វាយក្នុងមជ្ឈិមយាមសោត គាត់នឹងបាននូវប្រមាណ៨នៃវត្ថុទាំង

ពួង, ប៉ុន្តែព្រោះតែគាត់ថ្វាយក្នុងវេលាជិតភ្លឺ ទើបគាត់បាននូវប្រមាណនៃវត្ថុទាំងពួង ពិតណាស់ បុគ្គលកាលបើមានចិត្តកើតឡើងថាយើងនឹងធ្វើនូវអំពើជាកុសល មិនគួរញ៉ាំងចិត្តដែលកើតឡើងនោះឲ្យសាបសូន្យឡើយ គួរតែធ្វើក្នុងខណៈនោះឯង, ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរដល់បានទទួលផល ក៏យឺតយូរដែរ ព្រោះហេតុដូច្នោះ គប្បីធ្វើអំពើជាកុសលក្នុងលំដាប់នៃចិត្តប្បាទមែនពិត, កាលនឹងទ្រង់បន្ត អនុសន្ធិដើម្បីសំដែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

**១ អភិត្ថរេថ កល្យាណេ បាបា ចិត្តំ និវារយេ**
**ទន្ធំ ហិ ករតោ បុញ្ញំ បាបស្មឹ រមតី មនោ ។**

បុគ្គល គួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អភិត្ថរេថ** សេចក្តីថា គប្បីធ្វើភ្លាមៗ គឺថាឲ្យឆាប់ៗ ពិតណាស់ គ្រហស្ថកាលបើចិត្ត

កើតឡើងថា នឹងធ្វើកុសលណាមួយ មានកុសលទានទាំងឡាយ មានថ្វាយសលាកភត្តជាដើម គួរធ្វើភ្លាមៗ គឺថាធ្វើឲ្យឆាប់ៗ ដោយគិតថា យើងនឹងធ្វើមុន យើងនឹងធ្វើមុន កុំឲ្យជនដទៃ បានឱកាសឲ្យសោះ ។ ឬបើបព្វជិត កាលធ្វើវត្តទាំងឡាយ មានឧបជ្ឈាយវត្តជាដើម មិនឲ្យឱកាសដល់បព្វជិតដទៃ គួរធ្វើឲ្យឆាប់ៗ ដោយគិតថា យើងនឹងធ្វើមុនៗ ។

ពីរបទថា **បាបា ចិត្តំ** សេចក្តីថា បុគ្គលគប្បីហាមចិត្តចាកបាបកម្ម មានកាយទុច្ចរិតជាដើម ឬអកុសលចិត្តប្បាទក្នុងទីទាំងពួង ។

ពីរបទថា **ទន្ធំ ហិ ករតោ** សេចក្តីថា បុគ្គលណានៅគិតយ៉ាងនេះថា យើងនឹងឲ្យទាន, នឹងយើងធ្វើបុណ្យ, តើផលនឹងសម្រេចដល់យើង ឬក៏មិនសម្រេចទេ? ឈ្មោះថាធ្វើបុណ្យយឺតយូរ ដូចជាបុគ្គលដើរតាមផ្លូវរអិល, ចិត្តបាបរបស់បុគ្គលនោះ រមែងបានឱកាស ដូចមច្ឆរយចិត្ត ១០០០ ដួង របស់ព្រាហ្មណ៍ ឈ្មោះឯកសាដកដូច្នោះ ។ កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ដូច្នេះ ចិត្តរបស់បុគ្គលនោះ

រមែងត្រេកអរក្នុងបាប, ព្រោះថា ក្នុងវេលាដែលធ្វើកុសលកម្មប៉ុណ្ណោះ ចិត្តរមែងត្រេកអរក្នុងកុសល, ផុតអំពីនោះហើយ រមែងបង្អោនទៅកាន់អំពើអាក្រក់ដោយពិត ។

ក្នុងវេលាចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផល ។l៚

( រឿងព្រាហ្មណ៍ឈ្មោះចូឡេកសាដក ចប់ )

*************

# ២ រឿងព្រះសេយ្យកត្ថេរ

## *សេចក្ដីខាងដើម*

*ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសេយ្យកត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “**បាបញ្ចេ បុរិសោ កយិរា**” ជាដើម ។*

## *ព្រះថេរៈធ្វើបឋមសង្ឃាទិសេស*

*មានសេចក្ដីតំណាលថា ព្រះសេយ្យកត្ថេរនោះ ជាសទ្ធិវិហារិករបស់ព្រះលោឡុទាយិត្ថេរ ក្នុងកាលដែលលោកកើតការអផ្សុក មិនត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចារិយ ក៏បានប្រាប់សេចក្ដីនោះចំពោះព្រះលោឡុទាយី ត្រូវព្រះលោឡុទាយីបបួលឲ្យធ្វើបឋមសង្ឃាទិសេស ក្នុងកាលដែលលោកអផ្សុកខ្លាំង លោកក៏បានប្រព្រឹត្តកម្មនោះ ។*

## *កម្មអាក្រក់ឲ្យទុក្ខក្នុងភពទាំងពីរ*

*ព្រះសាស្ដា ទ្រង់ព្រះសណ្ដាប់នូវកិរិយារបស់លោកហើយ ត្រាស់ឲ្យហៅលោកមក ទ្រង់ត្រាស់សួរថា “ម្នាលសេយ្យក អ្នកបានធ្វើយ៉ាងនោះពិតឬ ?” កាលលោកទូលថា*

“បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះពិតមែន” ទើបទ្រង់ត្រាស់ថា “នែមោឃបុរស ព្រោះហេតុអ្វី បានជាអ្នកធ្វើកម្មដ៏ធ្ងន់ជាកម្មមិនសមគួរយ៉ាងនេះ ?” ទ្រង់តិះដៀលដោយប្រការផ្សេងៗហើយ ទ្រង់បញ្ញត្តសិក្ខាបទហើយ ទ្រង់ត្រាស់ថា “កម្មបែបនេះ ជាកម្មញុំាងសត្វឲ្យ ប្រព្រឹត្តទៅដើម្បីសេចក្តីទុក្ខតែម្យ៉ាងប៉ុណ្ណោះ ទាំងក្នុងភពនេះទាំងភពខាងមុខ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសំដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**២ បាបញ្ចេ បុរិសោ កយិរា ន នំ កយិរា បុនប្បុនំ**
**ន តម្ហិ ឆន្ទំ កយិរាថ ទុក្ខោ បាបស្ស ឧច្ចយោ ។**

បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយៗ ឡើយ
កុំគប្បីធ្វើសេចក្តីពេញចិត្តក្នុងបាបនោះ ( ព្រោះថា )
ការសន្សំបាប តែងនាំសេចក្តីទុក្ខមកឲ្យ ។

## អធិប្បាយគាថា

ព្រះគាថានោះមានសេចក្តីថា បើបុគ្គលធ្វើកម្មលាមកម្តង, គួរពិចារណាក្នុងខណៈនោះឯងថា កម្មនេះ ជាកម្មមិនសមគួរ ជាកម្មគ្រោតគ្រាត ( បុគ្គល) មិនគួរធ្វើកម្មនោះរឿយៗឡើយ, គប្បីបន្ទោបង់ចេញ មិនគួរធ្វើសេចក្តីពេញចិត្ត

ឬសេចក្តីត្រេកអរក្នុងបាបនោះឡើយ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះថា ការសន្សំ គឺការចំរើនបាប ជាហេតុឲ្យកើតទុក្ខ គឺរមែងនាំតែទុក្ខមកឲ្យ ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ-ផល ទាំងឡាយ មានសោតាបត្តិផលជាដើម ។៚

( រឿងព្រះសេយ្យកត្ថេរ ចប់ )

***********

# ៣ រឿងនាងលាជទេវធីតា

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងលាជទេវធីតា ត្រាស់ព្រះធម្មទេសនានេះថា “**បុញ្ញញ្ចេ បុរិសោ កយិរា**” ជាដើម ។

រឿងនេះបានកើតឡើងនៅក្នុងក្រុងរាជគ្រឹះ ។

## ស្ត្រីថ្វាយលាជចំពោះព្រះមហាកស្សបះ

សេចក្តីពិស្តារថា ព្រះមហាកស្សបៈ កាលដែលលោកគង់នៅឯបិប្ផលិគុហា លោកបានចូលនិរោធសមាបត្តិហើយចេញក្នុងថ្ងៃទី ៧ ពិចារណាមើលនូវទីត្រាច់ទៅដើម្បីភិក្ខាដោយទិព្វចក្ខុ ឃើញស្ត្រីថែរក្សាស្រែស្រូវសាលីម្នាក់ដែលកំពុងក្តិចកួរស្រូវសាលីលីងធ្វើជាលាជ លុះឃើញហើយ ក៏ពិចារណាទៀតថា ស្ត្រីនេះមានសទ្ធាឬក៏មិនមានទេ ? ដឹងថាមានសទ្ធា ក៏ពិចារណាទៀតថា នាងនឹងអាចសង្គ្រោះយើង ឬក៏មិនអាចទេ ដឹងថា កុលធីតានោះជាស្ត្រីឈ្លាសវៃ នឹងសង្គ្រោះយើង,លុះធ្វើហើយ នឹងបានសម្បត្តិ

ជាច្រើន ទើបឃ្លុំចីវរប្រដាប់បាត្រ និមន្តទៅឈរនៅជិតស្រែស្រូវសាលីនោះ ។ កុលធីតានោះគ្រាន់តែបានឃើញព្រះថេរៈភ្លាមក៏មានចិត្តជ្រះថ្លា មានសរីរៈដែលបីតិ ៥ប្រការពាល់ត្រូវហើយបានពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើនសូមលោកម្ចាស់ឈប់សិន" កាន់លាជដើរទៅចូលដោយរហ័ស លុះចូលដល់ព្រះថេរៈ ចាក់លាជទៅក្នុងបាត្ររបស់ព្រះថេរៈ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ធ្វើសេចក្ដីប្រាថ្នាថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមឲ្យនាងខ្ញុំម្ចាស់មាននូវចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយ ។

## ចិត្តជ្រះថ្លាក្នុងទានទៅកើតក្នុងឋានសួគ៌

ព្រះថេរៈ បានធ្វើអនុមោទនាថា សេចក្ដីប្រាថ្នាដែលនាងប្រាថ្នាហើយ ចូរសម្រេចចុះ ។ ចំណែកនាងលាជថ្វាយបង្គំព្រះថេរៈហើយ ត្រឡប់ទៅវិញដោយនឹកដល់ទានដែលខ្លួនថ្វាយហើយបណ្ដើរដើរទៅបណ្ដើរ ។ តាមភ្លឺស្រែដែលនាងធ្វើដំណើរទៅនោះមានអាសិរពិសដេកនៅក្នុងរន្ធមួយ ។ វាមិនអាចចឹកស្មងព្រះបាទរបស់ព្រះថេរៈដែលបិទបាំងដោយសំពត់កាសាយៈបាន ។ កាលដែលនាងដើរបណ្ដើរនឹក

ដល់ទានបណ្ដើរ ធ្វើដំណើរទៅដល់ទីនោះ វាក៏លូនចេញអំពីរន្ធខាំនាងឲ្យដួលដេកនៅក្នុងទីនោះឯង ។ នាងមានចិត្តជ្រះថ្លា ធ្វើមរណកាលហើយទៅកើតនៅក្នុងវិមានមាស ប្រមាណ ៣០ យោជន៍ ក្នុងឋានតាវត្តិង្ស មានអត្តភាព ៣ គាវុត ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ហាក់ដូចជាភ្ញាក់ឡើងអំពីការដេកលក់ដូច្នោះ ។

## វិធីធ្វើទិព្វសម្បត្តិឲ្យមាំមួន

នាងស្លៀកសំពត់ទិព្វប្រមាណ ១២ ហត្ថ មួយផ្ទាំង ដណ្ដប់មួយផ្ទាំង មាននាងទេពអប្សរ១.០០០ជាបរិវារ ដើម្បីប្រកាសបុព្វកម្ម ទើបឈរនៅត្រង់ទ្វារវិមាន ដែលប្រដាប់ដោយផ្ដិលមាសពេញដោយលាជមាស ព្យួររយោងរយោង ក្រឡេកមើលសម្បត្តិរបស់ខ្លួនហើយ ពិចារណាដោយទិព្វចក្ខុថា“យើងបានធ្វើកម្មអ្វីហ្ន៎ ទើបបានសម្បត្តិនេះ” បានដឹងថា“សម្បត្តិនេះយើងបានដោយសារផលនៃលាជដែលយើងបានថ្វាយចំពោះលោកម្ចាស់មហាកស្សបៈ” ។ នាងគិតថា “យើងបានសម្បត្តិបែបនេះ ព្រោះអាស្រ័យកម្មបន្តិចបន្តួចយ៉ាងនេះ ឥឡូវនេះ យើងមិនគួរប្រមាទទេ, យើងគួរតែធ្វើ

វត្តបដិបត្តិបំរើលោកដើម្បីធ្វើសម្បត្តិនេះឲ្យមាំមួន” លុះគិតដូច្នោះហើយ ក៏បានកាន់យកអំបោសនិងកញ្ច្រែងសំរាប់ចាក់សំរាមដែលធ្វើអំពីមាស ទៅបោសបរិវេណរបស់ព្រះថេរៈ ហើយតំកល់ទឹកឆាន់និងទឹកប្រើប្រាស់ទុកអំពីព្រលឹម ។

ព្រះថេរៈឃើញដូច្នោះ ក៏សំគាល់ថា ជាវត្តរបស់ភិក្ខុកំលោះ ឬសាមណេររូបណាមួយ ។ សូម្បីថ្ងៃទី ២ នាងក៏បានធ្វើដូច្នោះទៀត ។ ចំណែកព្រះថេរៈ ក៏សំគាល់ដូច្នោះទៀត ។ ប៉ុន្តែក្នុងថ្ងៃទី ៣ ព្រះថេរៈបានឮសំឡេងអំបោសដែលនាងបោស និងឃើញពន្លឺនៃសរីរៈរបស់នាងចាំងចូលទៅតាមប្រហោងសោ ក៏បើកទ្វារ ( ចេញមក ) សួរថា “នរណាបោសបរិវេណនោះ ?”

នាងលាជ. បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាជាឧបដ្ឋាយិការបស់លោកម្ចាស់ ឈ្មោះលាជទេវធីតា ។

ព្រះថេរៈ. ឧបដ្ឋាយិការបស់អាត្មា ដែលមានឈ្មោះយ៉ាងនេះ មើលទៅដូចជាមិនមាន ។

នាងលាជ. បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាជាអ្នកថែរក្សាស្រែស្រូវសាលី បានថ្វាយលាជចំពោះ

លោកម្ចាស់ហើយ មានចិត្តជ្រះថ្លា កំពុងតែធ្វើដំណើរត្រឡប់ទៅវិញត្រូវពស់ចឹក ធ្វើមរណកាលហើយ កើតក្នុងទេវលោកជាន់តាវត្តិង្ស, បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាគិតថា "សម្បត្តិនេះយើងបានព្រោះអាស្រ័យលោកម្ចាស់ ឥឡូវនេះ យើងនឹងធ្វើវត្តបដិបត្តិចំពោះលោកម្ចាស់ដើម្បីធ្វើសម្បត្តិឲ្យឋិតថេរ, ទើបខ្ញុំព្រះករុណាមកកាន់ទីនេះ ។

ព្រះថេរៈ. ទាំងថ្ងៃម្សិលមិញ ទាំងម្សិលម៉្ងៃ នាងបោសទីនេះ, នាងតំកល់ទឹកឆាន់ ទឹកប្រើប្រាស់ទុកឬ ?

នាងលាជ. ព្រះករុណា លោកម្ចាស់ ។

ព្រះថេរៈ. ម្នាលនាងទេវធីតា នាងចូរចៀសចេញទៅ, វត្តដែល នាងធ្វើហើយ ក៏ចាត់ទុកថានាងបានធ្វើហើយចុះ, ចាប់តាំងពីពេលនេះតទៅ នាងកុំមកកាន់ទីនេះទៀត ។

នាងលាជ. បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំញុំាងខ្ញុំព្រះករុណាឲ្យវិនាសឡើយ , សូមលោកម្ចាស់មេត្តាឲ្យខ្ញុំព្រះករុណាធ្វើវត្តបំរើលោកម្ចាស់ ដើម្បីធ្វើសម្បត្តិរបស់ខ្ញុំករុណាឲ្យគង់វង់ចុះ ។

ព្រះថេរៈ. ម្នាលនាងទេវធីតា នាងចូរចៀសចេញ, នាងកុំធ្វើឲ្យអាត្មាត្រូវព្រះធម្មកថិកទាំងឡាយ ដែលអង្គុយលើធម្មាសនៈចាប់ផ្ចិតដ៏វិចិត្រពោលក្នុងអនាគតថា បានឮថា មាននាងទេវធីតាម្នាក់មកធ្វើវត្តបដិបត្តិ តំកល់ទឹកឆាន់ ទឹកប្រើប្រាស់ដើម្បីព្រះមហាកស្សបត្ថេរ,ចាប់អំពីពេលនេះតទៅ នាងកុំមកកាន់ទីនេះឲ្យសោះ នាងចូរត្រឡប់ទៅវិញចុះ ។ នាងលាជទេវធីតានៅតែអង្វរព្រះថេរៈដដែលៗទៀតថាសូមលោកម្ចាស់កុំឲ្យខ្ញុំព្រះករុណាវិនាសឡើយ ។

ព្រះថេរៈគិតថា "នាងទេវធីតានេះមិនស្តាប់ពាក្យរបស់យើង" ទើបទះដៃដោយពោលថា "នាងមិនស្គាល់ប្រមាណរបស់ខ្លួន" ។

នាងមិនអាចឋិតនៅទីនោះបាន ហោះឡើងកាន់អាកាសផ្គងអញ្ជលីឈរស្រែកយំខ្សឹកខ្សួលក្នុងអាកាសថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំឲ្យសម្បត្តិដែលខ្ញុំព្រះករុណាបានហើយវិនាសឡើយ, សូមឲ្យខ្ញុំព្រះករុណាធ្វើសម្បត្តិឲ្យមាំមួនផង ។

## បុណ្យឲ្យកើតសុខក្នុងភពទាំងពីរ

ព្រះសាស្តា ទ្រង់គង់នៅក្នុងព្រះគន្ធកុដិ ទ្រង់បានឮសំឡេងទេវធីតានោះស្រែកយំ ទ្រង់ផ្សាយព្រះរស្មីទៅ ហាក់ដូចជាទ្រង់គង់ត្រាស់នៅក្នុងទីចំពោះមុខនាងទេវធីតាដូច្នោះ រួចត្រាស់ថា"ម្នាលទេវធីតា ការសង្រួមជាភារៈរបស់កស្សបៈបុត្ររបស់តថាគត, ប៉ុន្តែការកំណត់ដឹងថា នេះជាប្រយោជន៍របស់យើង ហើយប្រាថ្នាធ្វើតែបុណ្យជាភារៈរបស់ អ្នកត្រូវការបុណ្យ, ព្រោះថា ការធ្វើបុណ្យជាហេតុឲ្យកើតសុខទាំងក្នុងលោកនេះទាំងក្នុងលោកខាងមុខ លុះទ្រង់ត្រាស់ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសំដែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

៣ បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ
តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ។

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឲ្យរឿយៗ គួរធ្វើសេចក្តីពេញចិត្តក្នុងបុណ្យនោះ ( ព្រោះថា ) ការសន្សំបុណ្យ តែងនាំសេចក្តីសុខមកឲ្យ ។

# អធិប្បាយគាថា

សេចក្តីនៃព្រះគាថានោះថា "ប្រសិនបើបុរសធ្វើបុណ្យ

សោត, មិនគប្បីលះបង់ដោយយល់ថា "យើងធ្វើបុណ្យម្ដងហើយ, យើងធ្វើបុណ្យប៉ុណ្ណោះល្មមហើយ"ទេ គប្បីធ្វើឲ្យរឿយៗ សូម្បីក្នុងខណៈធ្វើបុណ្យនោះ គប្បីធ្វើសេចក្ដីពេញចិត្ត គឺញុំាងឆន្ទៈឲ្យកើតឡើងក្នុងការបំពេញបុណ្យ បានដល់ឲ្យកើតឧស្សាហ៍ក្នុងការបំពេញបុណ្យនោះ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះការសន្សំបុណ្យឲ្យកើតសុខ អធិប្បាយថា ព្រោះថា ការសន្សំគឺការចំរើនបុណ្យ ឈ្មោះថា ឲ្យកើតសុខ ព្រោះជាហេតុនាំសេចក្ដីសុខមកឲ្យទាំងក្នុងលោកនេះទាំងក្នុងលោកខាងមុខ ។

ក្នុងវេលាចប់ទេសនា ទេវធីតានោះឈរនៅក្នុងទីបំផុតផ្លូវ ៤៥ យោជន៍ទុំះឯង បានសម្រេចសោតាបត្តិផល ៕

( រឿងលាជទេវធីតា ចប់ )

**************

# ៤ រឿងអនាថបិណ្ឌិកសេដ្ឋី

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ អនាថបិណ្ឌិកសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះថា “**បាបោបិ បស្សតិ ភទ្រំ**” ជាដើម ។

## សេដ្ឋីទំនុកបំរុងភិក្ខុសាមណេរជានិច្ច

សេចក្ដីពិស្ដារថា អនាថបិណ្ឌិកសេដ្ឋី ចំណាយទ្រព្យ ៥៤ កោដិ កសាងវិហារ, កាលព្រះសាស្ដាទ្រង់នៅក្នុងវត្ត ជេតពន, ទៅកាន់វត្តមួយថ្ងៃ ៣ ដងរាល់ៗថ្ងៃ, មុននឹងគាត់ ធ្វើដំណើរទៅកាន់វត្ត គាត់បានគិតថា សាមណេរក្ដី ភិក្ខុ កំលោះក្ដី គប្បីក្រឡេកមើលដៃរបស់យើង ដោយនឹកថា សេដ្ឋីនោះកាន់វត្ថុអ្វីមកខ្លះ ដូច្នេះហើយ ទើបគាត់មិនដែល ធ្វើដំណើរទៅកាន់វត្តដោយដៃទទេឡើយ, កាលទៅវេលា ព្រឹកឲ្យមនុស្សកាន់បបរទៅ, បរិភោគអាហារព្រឹកហើយ ឲ្យ មនុស្សកាន់ភេសជ្ជៈទាំងឡាយមានទឹកដោះថ្លា ទឹកដោះខាប់ ជាដើមទៅ,ពេលរសៀល ឲ្យបំរើកាន់វត្ថុផ្សេងៗ មានកម្រង

ផ្កា គ្រឿងក្រអូប គ្រឿងលាបនិងសំពត់ជាដើម ទៅកាន់វិហារ, ថ្វាយទាន រក្សាសីល ដោយទំនងយ៉ាងនេះ រាល់ៗថ្ងៃជានិច្ច ។

## ការអស់ទ្រព្យរបស់សេដ្ឋី

ក្នុងកាលតមក សេដ្ឋីដល់នូវការអស់ទៅនូវទ្រព្យសម្បត្តិ ។ទាំងពួកពាណិជក៏បានចងការទ្រព្យអំពីគាត់ ១៨ កោដិទៀត ។ ប្រាក់ ១៨ កោដិ ដែលជាសម្បត្តិនៃត្រកូលរបស់គាត់ ដែលកប់ទុកនៅក្បែរឆ្នេរស្ទឹងនោះ កាលច្រាំងបាក់ដោយសារទឹក ក៏ហូរចូលទៅកាន់មហាសមុទ្រ ។ ទ្រព្យរបស់លោកសេដ្ឋី បានដល់នូវការអស់ទៅដោយលំដាប់ដោយប្រការយ៉ាងនេះឯង ។

## សេដ្ឋីថ្វាយទានតាមមានតាមបាន

សូម្បីគាត់ធ្លាក់ខ្លួនក្រយ៉ាងនោះហើយក៏ដោយ ក៏គាត់នៅតែថ្វាយទានចំពោះសង្ឃជានិច្ច, គ្រាន់តែទេយ្យវត្ថុដែលគាត់ថ្វាយចំពោះសង្ឃនោះមិនប្រណីត ។ ថ្ងៃមួយ ត្រូវព្រះសាស្តាត្រាស់សួរថា "ម្នាលគហបតី ចុះទានក្នុងត្រកូលអ្នកនៅតែឲ្យទេឬ ?" ក៏ក្រាបទូលថា "បពិត្រព្រះអង្គដ៏

ចម្រើន ទានក្នុងត្រកូល ខ្ញុំព្រះអង្គនៅតែឲ្យ, គ្រាន់តែទាន
នោះ មានបាយចុងអង្ករនិងទឹកជ្រក់ជាគំរប់ពីរ" ។

## កាលចិត្តផូរផង់ទានដែលថ្វាយហើយមិនជារបស់សៅហ្មងឡើយ

គ្រានោះ ព្រះសាស្តាត្រាស់នឹងសេដ្ឋីថា "ម្នាលគហបតី អ្នកកុំគិតឡើយថា ទានរបស់យើងសៅហ្មង, ព្រោះថា កាលចិត្តប្រណីតផូរផង់ហើយ ទានដែលបុគ្គលបានថ្វាយចំពោះព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាដើម មិនឈ្មោះថា សៅហ្មងឡើយ, ម្នាលគហបតី ម្យ៉ាងទៀត អ្នកបានថ្វាយទានចំពោះព្រះអរិយបុគ្គល ៨ ពួកហើយ, អម្បាលតថាគត ក្នុងកាលជាវេលាមព្រាហ្មណ៍នោះ ធ្វើអ្នកជម្ពូទ្វីបទាំងអស់ឲ្យសំរាកកក្ខរស្រែ ញុំាងមហាទានឲ្យប្រព្រឹត្តទៅមិនបានទក្ខិណេយ្យបុគ្គលណាមួយ សូម្បីអ្នកដល់ត្រៃសរណៈ, ទក្ខិណេយ្យបុគ្គលរកបានដោយលំបាកដូច្នេះ," ព្រោះហេតុដូច្នោះ អ្នកកុំគិតឡើយថា ទានរបស់យើងសៅហ្មង រួចហើយបានត្រាស់វេលាមសូត្រឲ្យលោកសេដ្ឋីស្តាប់ ។

## ទេវតាជាស់តឿនសេដ្ឋីឲ្យឈប់បរិច្ចាគ

គ្រានោះ ទេវតាដែលអាស្រ័យនៅឰដ៏ខ្លោងទ្វារផ្ទះរបស់លោកសេដ្ឋី កាលព្រះសាស្ដា និងសាវកទាំងឡាយចូលទៅកាន់ផ្ទះ, មិនអាចនឹងនៅលើក្លោងទ្វារបាន ដោយតេជៈនៃព្រះសាស្ដានិងសាវកទាំងឡាយ បានគិតថា ព្រះសាស្ដានិងពួកសាវកនេះមិនអាចចូលទៅកាន់ផ្ទះនេះបានដោយប្រការណា, យើងនិងញុះញង់លោកសេដ្ឋីដោយប្រការនោះ សូម្បីកាលមុនយើងក៏មានបំណងនឹងពោលដែរប៉ុន្តែមិនអាចពោលពាក្យអ្វីៗបាន ព្រោះក្នុងកាលនោះគាត់នៅជាឥស្សរៈ (មិនទាន់ធ្លាក់ខ្លួនក្រ ) ឥឡូវនេះ គាត់ធ្លាក់ខ្លួនក្រហើយ, ប្រាកដជាជឿពាក្យរបស់យើងមិនខាន, លុះដល់វេលារាត្រីបានចូលទៅកាន់បន្ទប់ដ៏មានសិរីរបស់លោកសេដ្ឋីហើយឈរឰដ៏អាកាស ។

គ្រានោះ លោកសេដ្ឋីឃើញទេវតានោះហើយ សួរថា នរណានុ៎ះ ?

ទេវតា. បពិត្រមហាសេដ្ឋី ខ្ញុំជាទេវតាសណ្ឋិតនៅឰដ៏ខ្លោងទ្វារទី៤ របស់លោក មកនេះដើម្បីដាស់តឿនលោក ។

សេដ្ឋី. បើដូច្នោះ អញ្ជើញអ្នកនិយាយមកចុះ ។

ទេវតា.បពិត្រមហាសេដ្ឋី លោកមិនក្រឡេកមើលដល់កាលជាខាងក្រោយទេ ខំតែចំណាយទ្រព្យយ៉ាងច្រើនក្នុងសាសនារបស់ព្រះសមណគោតម, ឥឡូវនេះ លោកធ្លាក់ខ្លួនក្រហើយ នៅតែមិនលះបង់ការចំណាយទ្រព្យទៀត, ប្រសិនបើ លោកនៅតែប្រព្រឹត្តយ៉ាងនេះទៀត តែ២-៣ ថ្ងៃទៀត លោកប្រាកដជារកអាហារបរិភោគនិងគ្រឿងស្លៀកពាក់គ្មាន, តើលោកនៅត្រូវការព្រះសមណគោតមធ្វើអ្វីទៀត?, លោកចូរបញ្ឈប់ការបរិច្ចាគហួសកំឡាំង ហើយប្រកបការងារទាំងឡាយ ដើម្បីប្រមូលទ្រព្យសម្បត្តិទុកចុះ ។

សេដ្ឋី. នេះឬ ជាឱវាទដែលអ្នកឲ្យខ្ញុំនោះ ?

ទេវតា. អើ មហាសេដ្ឋី ។

សេដ្ឋី. ម្នាលទេវតា អ្នកចូរអញ្ជើញទៅវិញចុះ, ខ្ញុំនេះបុគ្គលដូចជាអ្នក សូម្បីទាំងរយទាំងពាន់ទាំងសែននាក់ ក៏មិនអាចធ្វើឲ្យខ្ញុំញាប់ញ័របានដែរ, អ្នកបានពោលពាក្យមិនសមគួរ ដូច្នេះអ្នកក៏សមគួរនឹងនៅក្នុងផ្ទះរបស់ខ្ញុំដែរ, អ្នកចូរចេញអំពីផ្ទះរបស់ខ្ញុំឲ្យឆាប់ៗ ។

# ទេវតាត្រូវសេដ្ឋីបណ្តេញមិនមានទីអាស្រ័យ

ទេវតានោះ ស្តាប់ពាក្យរបស់សេដ្ឋី ដែលជាសោតាបន្នអរិយសាវកហើយ មិនអាចទ្រាំនៅបាន ក៏នាំទារកទាំងឡាយចេញអំពីផ្ទះរបស់លោកសេដ្ឋី លុះចេញទៅហើយមិនមានកន្លែងនៅ ទើបគិតថា យើងនឹងញ៉ាំងលោកសេដ្ឋីឲ្យអត់ទោស ហើយនឹងនៅក្នុងទីដដែលនោះវិញ លុះដូច្នោះហើយ ក៏បានចូលទៅរកទេវបុត្រដែលរក្សាព្រះនគរ ប្រាប់នូវកំហុសដែលខ្លួនបានធ្វើហើយ ហើយពោលថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកជួយខ្ញុំនាំខ្ញុំទៅកាន់សំណាក់របស់លោកសេដ្ឋី ឲ្យគាត់អត់ទោសហើយ ឲ្យទីកន្លែងនៅដល់ខ្ញុំ ។ ទេវបុត្រប្រកែកដោយពោលថា នាងបានពោលពាក្យមិនសមគួរ, ខ្ញុំមិនអាចទៅកាន់សំណាក់របស់លោកសេដ្ឋីនោះបានទេ ។

ទេវតានោះ ក៏ទៅកាន់សំណាក់របស់មហារាជទាំង ៤ ក៏ត្រូវមហារាជទាំង ៤ ប្រកែកមិនព្រមជូនទៅកាន់សំណាក់សេដ្ឋី ទើបចូលទៅគាល់សក្កទេវរាជក្រាបទូលរឿងនោះឲ្យទ្រង់បានជ្រាប ហើយទូលអង្វរសក្កទេវរាជគួរឲ្យអាណិតថា

បពិត្រព្រះឧបបត្តិទេព ខ្ញុំព្រះអង្គមិនមានទីនៅ ត្រូវដឹកដៃទារកទាំងឡាយអន្ទេបអន្ទាប គ្មានទីពឹង, សូមមហារាជមេត្តាញ៉ាំងសេដ្ឋីឲ្យឲ្យនូវទីលំនៅដល់ខ្ញុំព្រះអង្គផងចុះ ។

## សក្កទេវរាជទ្រង់ប្រាប់ឧបាយដល់ទេវតា

គ្រានោះ សក្កទេវរាជ ត្រាស់នឹងទេវតានោះថា សូម្បីយើងក៏មិនហ៊ានពោលពាក្យអ្វីៗនឹងសេដ្ឋី ព្រោះហេតុនៃអ្នកដែរ , ប៉ុន្តែយើងនឹងប្រាប់ឧបាយមួយដល់អ្នក ។

ទេវតា. បពិត្រព្រះឧបបត្តិទេព ប្រពៃណាស់ សូមព្រះអង្គទ្រង់ព្រះករុណាត្រាស់ប្រាប់មកចុះ ។

សក្ក. ម្នាលទេវតា អ្នកចូរទៅចុះ អ្នកចូរក្លែងភេទជាស្មៀនរបស់សេដ្ឋី ហើយឲ្យបុគ្គលម្នាក់នាំសៀវភៅ ( បញ្ជីចងការប្រាក់ ) អំពីដៃលោកសេដ្ឋីមកហើយ យកទៅទារបំណុលដែលមានទ្រព្យ ១៨ កោដិ ដែលពួកឈ្មួញខ្ចីយកទៅ ដោយអានុភាពរបស់ខ្លួនហើយ នាំមកដាក់ឲ្យពេញក្នុងបន្ទប់ទទេ, ទ្រព្យ ១៨ កោដិដែលលិចចូលកាន់មហាសមុទ្រក្តី ទ្រព្យ ១៨ កោដិចំណែកដទៃដែលមិនមានម្ចាស់ មាននៅក្នុងទីឯណោះក្តី, ចូរប្រមូលទ្រព្យទាំងអស់

នោះមកដាក់ឲ្យពេញក្នុងបន្ទប់ទទេរបស់សេដ្ឋី លះធ្វើកម្ម បែបនេះឲ្យជាទណ្ឌកម្មហើយ សូមខមាទោសសេដ្ឋីចុះ ។

## សេដ្ឋីត្រឡប់មានទ្រព្យដូចដើម

ទេវតានោះ ទទួលយល់ព្រមដោយពាក្យថា ប្រពៃហើយ ព្រះឧបបត្តិទេព ហើយធ្វើនូវកម្មគ្រប់ៗ យ៉ាងតាមន័យដែលសក្កទេវរាជត្រាស់ប្រាប់ហើយនោះឯង ញុំាងបន្ទប់ដ៏មានសិរីរបស់លោកសេដ្ឋីឲ្យភ្លឺស្វាងហើយ ឋិតនៅឰដ៏អាកាស កាលលោកសេដ្ឋីសួរថា នរណានុ៎ះ ក៏ប្រាប់ថា បពិត្រមហាសេដ្ឋី ខ្ញុំជាទេវតាអន្ធពាល ដែលសណ្ឋិតនៅនិងខ្លោងទ្វារទី ៤ របស់លោក, ពាក្យណាដែលខ្ញុំបានពោលហើយក្នុងសំណាក់របស់លោក ដោយភាពល្ងង់ខ្លៅរបស់ខ្ញុំ, សូមលោកអត់នូវទោសនោះដល់ខ្ញុំផងចុះ, ព្រោះខ្ញុំបានធ្វើទណ្ឌកម្ម ដោយការប្រមូលទ្រព្យ ៥៤ កោដិ មកដាក់ទុកពេញបន្ទប់ទទេ តាមបញ្ជារបស់សក្កទេវរាជហើយ, ខ្ញុំកាលមិនមាននូវទីលំនៅ រមែងលំបាក ។

## សេដ្ឋីអត់ទោសឲ្យទេវតា

អនាថបិណ្ឌិកសេដ្ឋីគិតថា ទេវតានេះ ពោលថា

ទណ្ឌកម្មដែលខ្ញុំធ្វើហើយដូច្នេះ, ហើយដឹងនូវទោសកំហុសរបស់ខ្លួន, យើងនឹងនាំទេវតានោះទៅគាល់ព្រះសម្មាសម្ពុទ្ធ ។ សេដ្ឋីនាំទេវតានោះទៅកាន់សំណាក់របស់ព្រះសាស្តា ក្រាបទូលនូវអំពើដែលទេវតានោះបានធ្វើហើយទាំងអស់ ។

ទេវតានោះក្រាបចុះទៀបព្រះយុគលបាទនៃព្រះសាស្តា ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនជ្រាបព្រះគុណទាំងឡាយរបស់ព្រះអង្គ បានពោលពាក្យដ៏អាក្រក់ៗគ្រោតគ្រាត ព្រោះភាពជាបុគ្គលអន្ធពាល សូមព្រះអង្គទ្រង់អត់នូវទោសនោះដល់ខ្ញុំព្រះអង្គផងចុះ, ( ទេវតា )សូមខមាទោសព្រះសាស្តាហើយ ទើបសូមខមាទោសមហាសេដ្ឋីក្រោយ ។

## កាលកម្មឲ្យផលជនពាលទើបឃើញត្រូវតាមពិត

ព្រះសាស្តា មុននឹងទ្រង់ឱវាទសេដ្ឋីនិងទេវតាដោយអំណាចវិបាកនៃកម្មល្អ និងកម្មអាក្រក់នោះឯង ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី បុគ្គលអ្នកធ្វើបាបក្នុងលោកនេះ ដរាបណាដែលបាបមិនទាន់ឲ្យផល,ដរាបនោះ បុគ្គលរមែងឃើញបាបថាល្អ ប៉ុន្តែកាលណាបាបរបស់គេឲ្យផល, កាល

នោះគេរមែងឃើញបាបថាអាក្រក់ពិតៗ, ចំណែកបុគ្គលអ្នកធ្វើបុណ្យ រមែងឃើញបុណ្យថាអាក្រក់ ដរាបណាដែលបុណ្យមិនទាន់ឲ្យផល, ប៉ុន្តែកាលណាបុណ្យរបស់គេឲ្យផល, កាលនោះ គេរមែងឃើញបុណ្យថាល្អពិតៗ ។ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានភាសិតគាថាទាំងនេះថា ៖

៤ បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ (បាបោ) បាបានិ បស្សតិ
ភទ្រោបិ បស្សតី បាបំ យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតី ភទ្រំ អថ (ភទ្រោ) ភទ្រានិ បស្សតិ ។

បាបមិនទាន់ឲ្យផលដរាបណា មនុស្សបាប ក៏នៅឃើញតែសេចក្តីចំរើនដរាបណោះ លុះកាលណាបាបឲ្យផល មនុស្សបាប ទើបឃើញបាបក្នុងកាលនោះ ។

អំពើល្អមិនទាន់ឲ្យផលដរាបណា មនុស្សល្អនៅឃើញតែបាបដរាបណោះ លុះកាលណា អំពើល្អឲ្យផល មនុស្សល្អ ទើបឃើញល្អក្នុងកាលនោះ ។

## អធិប្បាយគាថា

បុគ្គលអ្នកប្រកបដោយបាបកម្ម មានកាយទុច្ចរិត ជាដើម ឈ្មោះថា មនុស្សបាបក្នុងព្រះគាថានោះ ។ ក៏មនុស្សបាបនោះ កាលនៅសោយសុខដែលកើតឡើង ដោយអានុភាពនៃសុចរិតកម្មក្នុងកាលមុន រមែងឃើញបាបថាល្អ ។

បាទព្រះគាថាថា **យាវ បាបំ ន បច្ចតិ** ជាដើម សេចក្ដីថា បាបកម្មរបស់បុគ្គលនោះ នៅមិនទាន់ឲ្យផលក្នុងបច្ចុប្បន្នភព ឬសម្បរាយភព ( អ្នកធ្វើបាប រមែងឃើញបាប ថាល្អដរាបនោះ ) ។ ប៉ុន្តែកាលណាបាបកម្មរបស់គេនោះឲ្យផលក្នុងបច្ចុប្បន្នភព ឬសម្បរាយភព, កាលនោះ អ្នកធ្វើបាបនោះ កាលសោយកម្មករណ៍ផ្សេងៗ ក្នុងបច្ចុប្បន្ន និងទុក្ខក្នុងអបាយ ក្នុងសម្បរាយភព រមែងឃើញបាបថា អាក្រក់ជូរជាតិពិតមែន ។

ក្នុងព្រះគាថាទី ២ ( គប្បីជ្រាបសេចក្ដីដូចតទៅនេះ ) បុគ្គលអ្នកប្រកបដោយកម្ម មានកាយសុចរិតកម្មជាដើម ឈ្មោះថា មនុស្សល្អ, មនុស្សល្អនោះ កាលសោយទុក្ខដែលកើតឡើងដោយអានុភាពនៃទុច្ចរិតក្នុងកាលមុន រមែងឃើញអំពើល្អថា អាក្រក់ ។

បាទព្រះគាថាថា **យាវ កទ្រំ ន បច្ចតិ** ជាដើម សេចក្តីថា អមពើល្អរបស់មនុស្សល្អនោះ នៅមិនទាន់ឲ្យផល ក្នុងបច្ចុប្បន្នកព ឬសម្បរាយកពត្រឹមណា ( មនុស្សល្អ រមែងឃើញអំពើល្អ ថាអាក្រក់ ត្រឹមនោះ ) ។ ប៉ុន្តែកាលណាអំពើល្អនោះឲ្យផល, កាលនោះ មនុស្សល្អនោះ កាលសោយសុខដែលអាស្រ័យអាមិស មានលាភ និងសក្ការៈជាដើម ក្នុងបច្ចុប្បន្នកព និងសុខដែលអាស្រ័យសម្បត្តិដែលជាទិព្វក្នុងសម្បរាយកព រមែងឃើញកម្មល្អថាល្អពិតៗ ។

លុះចប់ទេសនា ទេវតានោះបានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះធម្មទេសនាបានជាកថា មានប្រយោជន៍ដល់បរិស័ទដែលមកប្រជុំគ្នាទីនោះឯង ៕៚

( រឿងអនាថបិណ្ឌិកសេដ្ឋី ចប់ )

**************

# ៥ រឿងភិក្ខុមិនចេះទុកដាក់បរិក្ខារ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ដែលមិនចេះទុកដាក់បរិក្ខារ ត្រាស់ព្រះធម្មទេសនានេះ ថា “**មាវមញ្ញេថ បាបស្ស**” ជាដើម ។

## របស់សង្ឃប្រើហើយគួរប្រញាប់យក មកទុកដាក់វិញ

បានឮថា ភិក្ខុនោះយកបរិក្ខារមានគ្រែនិងតាំងជាដើមទៅប្រើប្រាស់ខាងក្រៅហើយ ទុកចោលនៅទីនោះឯង បរិក្ខាររមែងវិនាសទៅព្រោះភ្លៀងខ្លះ កំដៅថ្ងៃខ្លះ ពួកសត្វមានកណ្តៀរជាដើមខ្លះ ។ កាលទាំងឡាយភិក្ខុជាស់តឿនថា ម្នាលអ្នកមានអាយុ ធម្មតាបរិក្ខារ ភិក្ខុគួរប្រើប្រាស់និងទុកដាក់ឲ្យបានមិនមែនឬ ? ត្រឡប់ជាពោលថា ម្នាលអាវុសោ កម្មដែលខ្ញុំធ្វើនោះតិចតួចណាស់, បរិក្ខារនោះមិនមានចិត្ត, ការវិចិត្រក៏មិនមាន ដូច្នេះហើយ នៅតែធ្វើដូច្នោះទៀត ។ ភិក្ខុទាំងឡាយក្រាបទូល អំពើរបស់លោកចំពោះព្រះសាស្តា។

ព្រះសាស្តា ត្រាស់ឲ្យហៅភិក្ខុនោះមកហើយ ត្រាស់សួរថា “ម្នាលភិក្ខុ អ្នកបានធ្វើយ៉ាងនោះពិតមែនឬ ?”សូម្បីត្រូវព្រះសាស្តាត្រាស់សួរ ក៏ក្រាបទូលរៀបមើលងាយយ៉ាងនេះថា “បពិត្រព្រះអង្គដ៏ចំរើន កម្មបន្តិចបន្តួចនោះនឹងជាអ្វី, កម្មដែលខ្ញុំព្រះអង្គធ្វើហើយនោះ មិនចាត់ថាជាកម្មដែលខ្ញុំព្រះអង្គបានធ្វើទេ, បរិក្ខារនោះមិនមានចិត្ត, ការវិចិត្រក៏មិនមាន ។

## កុំមើលងាយបាបថាតិចតួច

គ្រានោះ ព្រះសាស្តាត្រាស់នឹងលោកថា “ម្នាលភិក្ខុ ការដែលភិក្ខុទាំងឡាយធ្វើយ៉ាងនោះរមែងមិនសមគួរឡើយ ដែលឈ្មោះថា បាបកម្ម នរណាៗមិនគួរមើលងាយថាតិចតួចឡើយ, ដូចយ៉ាងថា ភាជនៈមានមាត់បើកដែលតំកល់ទុកកណ្តាលវាល កាលភ្លៀងធ្លាក់មករមែងមិនពេញដោយដំណក់ទឹកមួយដំណក់ក៏ពិតមែន,ក៏ប៉ុន្តែថា កាលភ្លៀងធ្លាក់មករឿយៗ ភាជនៈនោះរមែងពេញដោយពិតៗ យ៉ាងណាមិញ, បុគ្គលអ្នកធ្វើបាបកម្ម រមែងធ្វើគំនរបាបឲ្យចំរើនឡើងដោយលំដាប់បានយ៉ាងពិតប្រាកដដូច្នោះដែរ ដូច្នេះ

ហើយ, កាលនឹងទ្រង់ បន្តអនុសន្ធិដើម្បីសំដែងធម៌ ទើប ត្រាស់ព្រះគាថានេះថា ៖

**៥ មាវមញ្ញេថ បាបស្ស ន មត្តំ អាគមិស្សតិ**
**ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ**
**បូរតិ ពាលោ បាបស្ស ថោកំ ថោកំបិ អាចិនំ ។**

បុគ្គលមិនគួរមើលងាយបាបថា មានប្រមាណ តិចនឹងមិនឲ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយដំណក់ទឹកដែលធ្លាក់ចុះ យ៉ាង ណា បុគ្គលពាល កាលសន្សំបាប សូម្បីបន្តិចម្តងៗ គង់ពេញបានដោយបាប យ៉ាងនោះដែរ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **មាវមញ្ញេថ** សេចក្តីថា បុគ្គលមិនគួរមើលងាយ ។

បទថា **បាបស្ស** ប្រែថា នូវបាប ។

បាទព្រះគាថាថា **ន មត្តំ អាគមិស្សតិ** សេចក្តីថា បុគ្គលមិនគួរមើលងាយបាបយ៉ាងនេះថា យើងធ្វើបាប មាន ប្រមាណតិចតួច, កាលណាបាបនោះនឹងមកឲ្យផល ?

បទថា **ឧទកុម្ភោបិ** សេចក្ដីថា ភាជនៈដីប្រភេទណាមួយ ដែលគេបើកមាត់ទុកចោល ក្នុងវេលាភ្លៀងធ្លាក់ រមែងពេញដោយដំណក់ទឹក ដែលធ្លាក់ចុះសូម្បីម្ដងមួយដំណក់ៗ ដោយលំដាប់បាន យ៉ាងណា, បុគ្គលពាល កាលសន្សំ គឺកាលកពូនបាប សូម្បីម្ដងបន្តិចៗ រមែងពេញដោយបាបបាន ដូច្នោះដែរ ។

ក្នុងវេលាចប់ទេសនា ជនជាច្រើននាក់ បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ សូម្បីព្រះសាស្ដា ក៏ទ្រង់បញ្ញត្តសិក្ខាបទទុកថា ភិក្ខុយកកម្រាលរបស់សង្ឃក្រាលក្នុងទីវាលហើយ មិនយកមកទុកដាក់ដូចដើមវិញ ត្រូវអាបត្តិឈ្មោះនេះ ដូច្នេះឯង ៕

( រឿងភិក្ខុមិនចេះទុកដាក់បរិក្ខារ ចប់ )

*****************

# ៦ រឿងសេដ្ឋីឈ្មោះពិឡាលបទកៈ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះពិឡាលបទកៈ ( សេដ្ឋីជើងឆ្មា ) ត្រាស់ព្រះធម្មទេសនានេះថា “**មាវមញ្ញេថ បុញ្ញស្ស**” ជាដើម ។

## ឲ្យទានខ្លួនឯងនិងបបួលអ្នកដទៃបានសម្បត្តិពីរយ៉ាង

សេចក្ដីពិស្ដារថា សម័យមួយ អ្នកក្រុងសាវត្ថីនាំគ្នាថ្វាយចំពោះព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយរួបរួមគ្នាជាពួក ។ ថ្ងៃមួយ ព្រះសាស្ដា មុននឹងទ្រង់ធ្វើអនុមោទនា បានត្រាស់យ៉ាងនេះថា “ម្នាលឧបាសក ឧបាសិកាទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ឲ្យទានដោយខ្លួនឯង, ( ប៉ុន្ដែ ) មិនបបួលអ្នកដទៃ, បុគ្គលនោះរមែងបានភោគសម្បត្តិ, ( ប៉ុន្ដែ ) មិនមាននូវបរិវារសម្បត្តិ ក្នុងទីដែលខ្លួនកើតៗ, បុគ្គលខ្លះមិនឲ្យទានដោយខ្លួនឯង, បបួលតែអ្នកដទៃឲ្យធ្វើ, បុគ្គលនោះរមែង បានបរិវារសម្បត្តិ ( ប៉ុន្ដែ ) មិនមាននូវ

កោគសម្បត្តិក្នុងទីនៃខ្លួនកើត, បុគ្គលខ្លះមិនឲ្យទានដោយខ្លួនឯងផង មិនបបួលអ្នកដទៃផង, បុគ្គលនោះរមែងមិនមានទាំងកោគសម្បត្តិទាំងបរិវារសម្បត្តិក្នុងទីដែលខ្លួនកើត, ជាមនុស្សស៊ីដែល, បុគ្គលខ្លះទៀត ឲ្យទានដោយខ្លួនឯងផង បបួលអ្នកដទៃផង, បុគ្គលនោះរមែងបានទាំងកោគសម្បត្តិនិងបរិវារសម្បត្តិក្នុងទីដែលខ្លួនកើត ។

## បណ្ឌិតអំពាវនាវសុំរបស់ធ្វើបុណ្យ

គ្រានោះ បុរសជាបណ្ឌិតម្នាក់ ស្តាប់ព្រះធម៌ទេសនានោះហើយ គិតថា ឱ ! ហេតុនេះគួរឲ្យអស្ចារ្យណាស់, ឥឡូវនេះ យើងនឹងធ្វើកម្មដែលប្រព្រឹត្តទៅ ដើម្បីបាននូវសម្បត្តិទាំងពីរ, ទើបក្រាបទូលព្រះសាស្តាក្នុងវេលាដែលស្តេចក្រោកទៅថា "បពិត្រព្រះអង្គដ៏ចំរើន ស្អែកនេះ សូមព្រះអង្គទ្រង់ទទួលភិក្ខារបស់ពួកខ្ញុំព្រះអង្គ ។

ព្រះសាស្តា. ម្នាលឧបាសកអ្នកត្រូវការភិក្ខុប៉ុន្មានរូប ?

បុរសបណ្ឌិត. បពិត្រព្រះដ៏ចម្រើន ខ្ញុំព្រះអង្គត្រូវការភិក្ខុទាំងអស់ ។

ព្រះសាស្តាទ្រង់ទទួលហើយ បុរសជាបណ្ឌិតនោះ ក៏

ចូលទៅកាន់ស្រុកឃោសនាថា ម្នាលអ្នកទាំងឡាយ ខ្ញុំបាននិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដើម្បីឆាន់កត្តាហារក្នុងថ្ងៃស្អែកនេះ, អ្នកណាអាចថ្វាយដល់ភិក្ខុប៉ុន្មានរូប, អ្នកនោះចូរឲ្យវត្ថុផ្សេងៗមានអង្ករជាដើម ដើម្បីប្រយោជន៍ដល់អាហារមានយាគូជាដើម ដើម្បីភិក្ខុប៉ុណ្ណោះរូប, ពួកយើងនឹងឲ្យគេដាំស្លក្នុងទីមួយ ហើយថ្វាយទានជាមួយគ្នា ។

## ហេតុដែលសេដ្ឋីមានឈ្មោះថាពិឡាលបទកៈ

គ្រានោះ សេដ្ឋីម្នាក់ ឃើញបុរសនោះមកដល់រានផ្សាររបស់ខ្លួន ក៏ខឹងថា បុរសនេះ មិននិមន្តភិក្ខុឲ្យល្មមកំឡាំងរបស់ខ្លួន ចាំបាច់មកដើរបបួលអ្នកស្រុកទាំងអស់ធ្វើអ្វីទៀត, ទើបប្រាប់ថា ឯងចូរយកភាជនៈដែលឯងកាន់មក ដូច្នេះហើយយកម្រាមដៃ ៣ ចាប់យកអង្ករបន្តិច សណ្តែកខៀវបន្តិច សណ្តែកភជមាសបន្តិចឲ្យទៅបុរសនោះ ។ តាំងពីពេលនោះមក សេដ្ឋីនោះមានឈ្មោះថា ពិឡាលបទកសេដ្ឋី ( សេដ្ឋីជើងឆ្មា ) ។ សូម្បីកាលឲ្យនូវភេសជ្ជៈ មានទឹកដោះថ្លា និងទឹកអំពៅជាដើម ក៏ផ្អៀងចំពួយកំសៀវ ចូលទៅក្នុងក្អម ធ្វើចំពួយកំសៀវនោះឲ្យជាប់ជាមួយនឹងមាត់ក្អមឲ្យភេសជ្ជៈ មាន

ទឹកដោះថ្លានិងទឹកអំពៅជាដើម ហូរចុះទៅម្តងមួយដំណក់ៗ បានឲ្យត្រឹមបន្តិចបន្តួចប៉ុណ្ណោះ ។

ឧបាសកនោះដាក់វត្ថុទានដែលមនុស្សឲ្យរួមគ្នា ( ប៉ុន្តែ ) ដាក់របស់ដែលលោកសេដ្ឋីឲ្យដោយឡែកផ្សេងអំពីគេ ។

## សេដ្ឋីឲ្យមនុស្សជិតដិតទៅស៊ើបការធ្វើរបស់បុរសអ្នកដើរឃោសនា

សេដ្ឋីនោះ ឃើញអំពើរបស់ឧបាសកនោះហើយ គិតថា ហេតុអ្វី បុរសនេះ ចាំបាច់យករបស់ដែលយើងឲ្យទុកដោយឡែក ទើបប្រើកូនឈ្នួលម្នាក់ឲ្យទៅតាមក្រោយបុរសនោះ ដោយពោលថា ឯងចូរទៅ, ចូរដឹងនូវកម្មដែលគេធ្វើនោះ ។ ឧបាសកនោះទៅដល់រោងទានហើយ ពោលថា "សូមផលដ៏ធំចូរកើតមានដល់សេដ្ឋី," ដូច្នេះហើយ ដាក់អង្ករ ១-២ គ្រាប់ ដើម្បីប្រយោជន៍ដល់យាគូ កត្តនិងនំ, ដាក់សណ្តែកខៀវខ្លះ សណ្តែក រាជមាសខ្លះ ប្រេងមួយតក់និងទឹកអំពៅមួយតក់ទៅក្នុងភាជនៈគ្រប់ៗភាជនៈ ។ កូនឈ្នួលនោះបានទៅស៊ើបដឹងរឿងមកប្រាប់លោកសេដ្ឋី ។ សេដ្ឋីបានស្តាប់ពាក្យនោះហើយ គិតថា "ប្រសិនបើបុរសនោះពោល

ទោសយើងកណ្ដាលបរិស័ទមែននោះ គ្រាន់តែវានិយាយដល់ឈ្មោះរបស់យើងភ្លាមយើងនឹងប្រហារវាឲ្យស្លាប់ ។ព្រឹកឡើងសេដ្ឋីស្លៀតកូនកាំបិតនិងជាយសំពត់ស្លៀកហើយ ដើរទៅឈរនៅក្បែររោងទាន ។

## ធ្លាតនិយាយធ្វើឲ្យអ្នកមានបំណងអាក្រក់ត្រឡប់ជាមានចិត្តទន់ភ្លន់វិញ

បុរសនោះ អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយក្រាបទូលព្រះមានព្រះភាគថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានដើរបបួលមហាជនឲ្យថ្វាយទាននេះ, ពួកមនុស្សដែលខ្ញុំព្រះអង្គបបួលហើយបានឲ្យអង្ករជាដើមច្រើនខ្លះតិចខ្លះ តាមកំឡាំងរបស់ខ្លួន, សូមផលដ៏វិសាល ( ដ៏ច្រើន ) ចូរកើតមានដល់មហាជនទាំងអស់នោះចុះ" ។

សេដ្ឋីបានឮពាក្យនោះហើយ គិតថា យើងមកដោយតាំងចិត្តថា គ្រាន់តែវាលើកឈ្មោះរបស់យើងឡើងថា សេដ្ឋីឈ្មោះឯណោះកាន់យកអង្ករជាដើម ដោយម្រាមដៃបីឲ្យយើងក៏នឹងសម្លាប់បុរសនេះឲ្យស្លាប់, ប៉ុន្តែបុរសនេះបានធ្វើទានទាំងអស់រួមគ្នា ហើយពោលថា ទានដែលជនទាំងឡាយ

ណា វាស់ដោយនាឡិជាដើមហើយឲ្យក្តី, ទានដែលជនទាំង ឡាយណា កាន់យកដោយចិបម្រាមដៃហើយឲ្យក្តី, សូមផល ដ៏វិសាល ចូរកើតមានដល់ជនទាំងអស់នោះចុះ, បើយើងមិន ឲ្យបុរសរូបនេះអត់ទោសឲ្យទេ ទេវទណ្ឌនឹងធ្លាក់ចុះមកលើ ក្បាលរបស់យើងមិនខាន ។ សេដ្ឋីនោះ ក្រាបចុះទៀបជើង របស់ឧបាសកនោះហើយ ពោលថា បពិត្រនាយ សូមលោក អត់ទោសឲ្យខ្ញុំផង, ឧបាសកនោះសួរថា "បពិត្រសេដ្ឋី តើ មានរឿងអ្វី ?" ទើបប្រាប់រឿងនោះទាំងអស់ ។

ព្រះសាស្តាទ្រង់ឃើញកិរិយានោះហើយ ត្រាស់សួរអ្នក ខ្វល់ខ្វាយក្នុងទាននោះថា "ម្នាលឧបាសក តើមានរឿងអ្វី ?" អ្នកខ្វល់ខ្វាយក្នុងទាន ក្រាបទូលរឿងនោះទាំងអស់ តាំងអំពី ថ្ងៃដែលកន្លងទៅហើយចំពោះព្រះសាស្តា ។

## កុំមើលងាយបុណ្យថាមានប្រមាណតិច

គ្រានោះ ព្រះសាស្តាត្រាស់សួរសេដ្ឋីនោះថា "ម្នាល សេដ្ឋី តើរឿងនោះ យ៉ាងនោះពិតមែនឬ?" កាលលោក សេដ្ឋីក្រាបទូលថា "ព្រះករុណាព្រះអង្គ" ទ្រង់ត្រាស់ថា "ម្នាលឧបាសក ដែលឈ្មោះថា បុណ្យ នរណាៗមិនគួរ

មើលងាយថា មានប្រមាណតិចតួច” បុគ្គលថ្វាយទានចំពោះ ភិក្ខុសង្ឃហើយ មិនគួរមើលងាយថា ជារបស់តិចតួច ព្រោះ ថា បុរសជាបណ្ឌិត ធ្វើបុណ្យរមែងពេញទៅដោយបុណ្យ ដោយលំដាប់ ប្រៀបដូចភាជនៈដែលចំហមាត់ រមែងពេញ ទៅដោយទឹកដូច្នោះ ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិ ដើម្បីសម្ដែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

៦ មាវមញ្ញេថ បុញ្ញស្ស    ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន    ឧទកុម្ភោបិ បូរតិ
បូរតិ ធីរោ បុញ្ញស្ស    ថោកំ ថោកំបិ អាចិនំ ។

បុគ្គលមិនគួរមើលងាយបុណ្យថា មានប្រមាណ តិច នឹងមិនឲ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយដំណក់ទឹក ដែលធ្លាក់ចុះ យ៉ាង ណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្ដងៗ គង់ពេញបានដោយបុណ្យយ៉ាងនោះដែរ ។

## អធិប្បាយគាថា

សេចក្ដីនៃព្រះគាថានោះថា បុរសជាបណ្ឌិត ធ្វើបុណ្យ ហើយកុំមើលងាយ គឺមិនគួរមើលងាយបុណ្យ យ៉ាងនេះថា

យើងធ្វើបុណ្យមានប្រមាណតិច បុណ្យមានប្រមាណតិចនោះនឹងមិនមកដោយអំណាចនៃវិបាក, កាលបើដូច្នោះ កម្មបន្តិចបន្តួច នឹងឃើញយើងទីណា ឬថាយើងនឹងឃើញកម្មនោះទីណា កាលណាបុណ្យនោះនឹងមកឲ្យផល, ដូចយ៉ាងថាភាជនៈដីដែលគេបើកគ្រាបចំហមាត់ទុកកណ្ដាលវាល រមែងពេញដោយដំណក់ទឹកដែលធ្លាក់ចុះមក ( ម្ដងមួយដំណក់ៗ ) មិនដាច់ខ្សែយ៉ាងណា, ធីរជន គឺជនជាបណ្ឌិត កាលសន្សំបុណ្យបន្តិចម្ដងៗ ឈ្មោះថា ពេញដោយបុណ្យបានដូច្នោះដែរ ។

ក្នុងកាលចប់ទេសនា សេដ្ឋីនោះ បានសម្រេចសោតា-បត្តិផល ព្រះធម្មទេសនា ជាកថាមានប្រយោជន៍ដល់បរិស័ទដែលមកប្រជុំគ្នានៅទីនោះឯង ៕

( រឿងសេដ្ឋីឈ្មោះពិឡាលបទកៈ ចប់ )

***************

# ៧. រឿងមហាធនពាណិជ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពាណិជអ្នកមានទ្រព្យច្រើន បានត្រាស់ព្រះធម្មទេសនានេះថា "***វាណិជោវ ភយំ មគ្គំ***" ជាដើម ។

## ពាណិជនិមន្តភិក្ខុ ៥០០ រូប រួមដំណើរជាមួយគ្នា

បានឮថា ពួកចោរ ៥០០ នាក់ ស្វែងរកឱកាសដើម្បីប្លន់ទ្រព្យសម្បត្តិក្នុងផ្ទះរបស់ពាណិជ ប៉ុន្តែមិន បានឱកាស ។ សម័យក្រោយមក ពាណិជនោះផ្ទុករទេះ ៥០០ រទេះពេញដោយរបស់របរហើយ ឲ្យគេប្រាប់ភិក្ខុទាំងឡាយថា "យើងនឹងទៅកាន់ទីឯណោះដើម្បីជំនួញ, លោកម្ចាស់អង្គណាមានបំណងនិមន្តទៅកាន់ទីនោះ, សូមលោកម្ចាស់ទាំងនោះនិមន្តចេញទៅ, នឹងមិនលំបាកដោយភិក្ខាក្នុងដំណើរផ្លូវ" ។ ភិក្ខុ ៥០០ រូប ស្តាប់ដំណឹងនោះហើយ បាននិមន្តទៅជាមួយនឹងពាណិជនោះ ។ ឯចោរទាំងនោះបានដឹងពត៌មានថា " ពាណិជនោះចេញដំណើរទៅហើយ" បានទៅពួនស្ទាក់ចាំប្លន់ក្នុង

ដងព្រៃក្រាស់ ។

ចំណែកពាណិជទៅហើយ ឈប់សំរាកក្នុងស្រុកមួយក្បែរមាត់ព្រៃ ចាត់ចែងនូវពាហនៈទាំងឡាយមានគោ និងរទេះជាដើមរួចហើយ ថ្វាយភិក្ខាដល់ភិក្ខុទាំងនោះជាប់មិនដាច់អស់ ២-៣ ថ្ងៃ ។

## ពួកចោរប្រើមនុស្សឲ្យទៅស៊ើបដំណឹងពាណិជ

ចោរទាំងនោះកាលពាណិជយូរពេក មិនឃើញពាណិជមកសោះ ក៏ប្រើបុរសម្នាក់ឲ្យទៅដោយពាក្យថា "ឯងចូរទៅចូរដឹងនូវថ្ងៃជាទីចេញដំណើររបស់ពាណិជនោះ ហើយចូរមកវិញ" ។ បុរសនោះធ្វើដំណើរទៅដល់ស្រុកនោះហើយ សួរបុរសជាសំឡាញ់ម្នាក់ថា "ម្នាលសំឡាញ់ កាលណាទើបពាណិជនឹងចេញដំណើរ" សំឡាញ់នោះឆ្លើយថា "២-៣ ថ្ងៃទៀត" ឆ្លើយដូច្នេះហើយ សួរថា "ចុះអ្នកឯងសួរដើម្បីអ្វី ?" គ្រានោះ បុរសនោះប្រាប់សំឡាញ់នោះថា "ពួកខ្ញុំជាចោរ ៥០០ ពួននៅក្នុងព្រៃមួយដើម្បីប្លន់ពាណិជនោះ ។ ចំណែកសំឡាញ់ពោលថា"បើដូច្នោះ អ្នកចូរទៅចុះ, ពាណិជនឹងចេញទៅឆាប់ៗឥឡូវនេះហើយ" បញ្ជូនបុរសនោះទៅហើយ គិតថា

"តើយើងគួរហាមឃាត់ពួកចោរឬក៏ពាណិជ ?" សម្រេចចិត្តថា "តើមានប្រយោជន៍អ្វីដល់យើងដោយការប្រាប់ដំណឹងដល់ចោរទាំងនោះ ភិក្ខុ ៥០០ រូបចិញ្ចឹមជីវិតអាស្រ័យពាណិជ, យើងនឹងឲ្យដំណឹងដល់ពាណិជ ហើយបានទៅកាន់សំណាក់របស់ពាណិជនោះហើយ សួរថា "កាលណាលោកនឹងចេញដំណើរទៅ" ពាណិជប្រាប់ថា ៣ថ្ងៃទៀត" ក៏ពោលថា"លោកចូរធ្វើតាមពាក្យរបស់ខ្ញុំ, បានឮថា ពួកចោរ ៥០០ ពួនចាំប៉ូន់លោកនៅក្នុងដងព្រៃមួយ ដូច្នេះលោកកុំអាលធ្វើដំណើរទៅអី ។

## ពាណិជត្រូវចោរស្អាត់ត្រូវស្នាក់នៅក្នុងរវាងផ្លូវ

ពាណិជ. ហេតុអ្វី បានជាអ្នកដឹង ?

បុរសជាសំឡាញ់. ខ្ញុំមានសំឡាញ់ម្នាក់នៅក្នុងក្រុមចោរទាំងនោះ, ខ្ញុំដឹងព្រោះអាស្រ័យគេនិយាយប្រាប់ ។

ពាណិជ. បើដូច្នោះ តើមានប្រយោជន៍អ្វីដល់យើងដោយការចេញទៅអំពីទីនេះ, យើងនឹងត្រឡប់ទៅផ្ទះវិញ ។

កាលពាណិជនោះនៅបង្អែបង្អង់យូរពេក ចោរទាំងនោះក៏ប្រើបុរសនោះឲ្យមកម្តងទៀត បុរសនោះមកដល់ទីនោះ

ហើយសួរសំឡាញ់នោះ បានដឹងដំណឹងនោះហើយ ទៅប្រាប់ពួកចោរថា "បានឮថា ពាណិជនឹងត្រឡប់ទៅផ្ទះវិញ" ។ ពួកចោរស្តាប់ពាក្យនោះហើយបានចេញអំពីដងព្រៃនោះទៅស្ទាក់នៅក្បែរផ្លូវដទៃទៀត ។ កាលស្ទាក់ចាំពាណិជយូរពេក ក៏ប្រើបុរសនោះឲ្យទៅក្នុងសំណាក់របស់សំឡាញ់នោះម្តងទៀត ។ សំឡាញ់នោះដឹងថាពួកចោរស្ទាក់នៅក្នុងទីនោះហើយ ក៏ប្រាប់ពាណិជទៀត ។

ពាណិជគិតថា "សូម្បីយើងនៅទីនេះ ក៏មិនមានការខ្វះខាតអ្វីដែរ, បើដូច្នោះ យើងមិនទៅខាងណាទាំងអស់, យើងនឹងនៅទីនេះឯង" លុះគិតដូច្នេះហើយ ក៏ទៅកាន់សំណាក់របស់ភិក្ខុទាំងឡាយ ហើយប្រាប់ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន បានឮថា ពួកចោរមានបំណងនឹងប្លន់ខ្ញុំព្រះករុណាបានទៅពួនស្ទាក់នៅក្បែរផ្លូវមួយ, លុះបានដឹងថា ឥឡូវនេះខ្ញុំព្រះករុណាត្រឡប់ទៅផ្ទះវិញ ក៏ទៅពួនស្ទាក់នៅក្បែរផ្លូវទៀត,ខ្ញុំព្រះករុណានឹងមិនទៅខាងណាទាំងអស់, ខ្ញុំព្រះករុណានិងសំរាកនៅទីនេះសិន, លោកម្ចាស់ទាំងឡាយមានបំណងនឹងនៅទីនេះក៏នៅចុះ,មានបំណងនឹងនិមន្តទៅខាងណា ក៏និមន្ត

ទៅតាមសេចក្តីពេញចិត្តរបស់លោកម្ចាស់” ។

## ភិក្ខុលាពាណិជត្រឡប់ទៅក្រុងសាវត្ថី

ពួកភិក្ខុពោលថា “បើដូច្នោះ ពួកអាត្មានឹងត្រឡប់ទៅវិញ” លុះព្រឹកឡើង លាពាណិជនិមន្តទៅកាន់ក្រុងសាវត្ថី ទៅដល់វត្តជេតពនថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីដ៏សមគួរ ។

## វត្ថុដែលគួរវៀរ

ព្រះសាស្តាត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនបានទៅជាមួយពាណិជដែលអ្នកមានទ្រព្យច្រើនទេឬ ?” កាលពួកភិក្ខុទាំងនោះក្រាបទូលថា “ព្រះករុណាព្រះអង្គ ពួកចោរពួនស្ទាក់នៅក្បែរផ្លូវទាំងពីរខាងដើម្បីប្លន់ពាណិជដែលមានទ្រព្យច្រើន, ព្រោះហេតុនោះ ទើបពាណិជគាត់ស្នាក់នៅទីនោះឯង, ចំណែកពួកខ្ញុំព្រះអង្គលាគាត់ត្រឡប់មកវិញ” ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ពាណិជដែលមានទ្រព្យច្រើន រមែងវៀរផ្លូវដែលមានភ័យ ព្រោះមានពួកចោរ, សូម្បីបុរសដែលជាអ្នកប្រាថ្នានឹងរស់នៅ ក៏រមែងវៀរថ្នាំពិសដ៏ខ្លាំងក្លាដែរ, សូម្បីភិក្ខុជ្រាប ថា ភព ៣ ដូចជាផ្លូវ

ដែលពួកចោរចាំស្ទាក់, គួរតែវៀរអំពើអាក្រក់ចេញ ដូច្នេះហើយ កាលទឹងទ្រង់បន្តអនុសន្ធិដើម្បីសំដែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

**៧ វាណិជោវ ភយំ មគ្គំ អប្បសត្ថោ មហទ្ធនោ**
**វិសំ ជីវិតុកាមោវ បាបានិ បរិវជ្ជយេ ។**

បុគ្គលគួរចៀសវាងបាបទាំងឡាយ ឲ្យដូចពាណិជដែលមានទ្រព្យច្រើន តែមានគ្នាតិចចៀសវាងផ្លូវគួរខ្លាច ឬដូចជាបុរសប្រាថ្នារស់នៅ ចៀសវាងថ្នាំពិសដូច្នោះដែរ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ភយំ** បានដល់ ផ្លូវដែលគួរខ្លាច, អធិប្បាយថា ឈ្មោះថា មានភ័យចំពោះមុខ ព្រោះជាផ្លូវដែលពួកចោរពួនស្ទាក់ ។ លោកពោលអធិប្បាយពាក្យនេះទុកថា ពាណិជដែលមានទ្រព្យច្រើន តែមានគ្នាតិច ចៀសវាងផ្លូវដែលមានភ័យនៅចំពោះមុខយ៉ាងណា, អ្នកត្រូវការទឹងរស់នៅ រមែងវៀរថ្នាំពិស យ៉ាងណា, បណ្ឌិតគួរវៀរបាកកម្មអាក្រក់ទាំងឡាយ សូម្បីមានប្រមាណតិច

ចេញ ដូច្នោះដែរ ។

លុះចប់ទេសនា ភិក្ខុទាំងនោះ បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ។ ព្រះធម្មទេសនាបានជាកថាមានប្រយោជន៍ដល់មហាជនដែលមកប្រជុំគ្នានៅទីនោះ ។៚

( រឿងពាណិជអ្នកមានទ្រព្យច្រើន ចប់ )

## ៨. រឿងនាយព្រានកុក្កុដមិត្ត

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រានម្នាក់ឈ្មោះកុក្កុដមិត្ត បានត្រាស់ព្រះធម្មទេសនានេះថា "**បាណិម្ហិ ចេ វណោ នាស្ស**" ជាដើម ។

## ធីតាសេដ្ឋីស្រឡាញ់នាយព្រានកុក្កុដមិត្ត

បានឮថា នៅក្នុងក្រុងរាជគ្រឹះមានធីតាសេដ្ឋីម្នាក់ ចំរើនវ័យហើយ ដើម្បីរក្សាកូនស្រី ទើបមាតាបិតាប្រគល់ស្រីបំរើឲ្យម្នាក់ហើយឲ្យនៅក្នុងបន្ទប់ព្ធដ៏ខាងលើនៃប្រាសាទ ៧ ជាន់, នៅវេលាសៀលថ្ងៃមួយ នាងបានក្រឡេកមើលទៅថ្នល់តាមបង្អួច បានឃើញព្រានម្រឹគម្នាក់ឈ្មោះកុក្កុដមិត្ត ដែលកាន់

អន្ទាក់ ៥០០ និងស្នូ ៥០០ សម្រាប់ម្រឹគទាំងឡាយចិញ្ចឹមជីវិត សម្រាប់ម្រឹគ ៥០០ ហើយលើកដាក់លើររទេះបរចូលទៅកាន់ព្រះនគរដើម្បីលក់សាច់ ក៏មានចិត្តប្រតិពទ្ធព្រានម្រឹកនោះ បានឲ្យបណ្ណាការទៅស្រ្តីបំរើហើយ បញ្ជូនទៅដោយពាក្យថា នាងចូរនាំយកបណ្ណាការនេះទៅឲ្យបុរសនោះហើយ សួរឲ្យដឹងថាគាត់នឹងត្រឡប់ទៅវិញអង្កាល ហើយសឹមមកវិញ ។

ស្រ្តីបំរើនោះទៅដល់ទីនោះហើយ ឲ្យបណ្ណាការដល់ព្រានម្រឹគនោះ ហើយសួរថា កាលណាលោកនឹងត្រឡប់ទៅវិញ ? នាយព្រានឆ្លើយតបថា ថ្ងៃនេះយើងលក់សាច់អស់ហើយ នឹងចេញទៅតាមទ្វារឈ្មោះឯណោះអំពីព្រលឹម ។ ស្រ្តីបំរើស្តាប់ពាក្យដែលនាយព្រាននោះប្រាប់ហើយ ត្រឡប់មកប្រាប់សេដ្ឋីធីតា ។

## សេដ្ឋីធីតាលួចរត់ចេញទៅតាមនាយព្រាន

សេដ្ឋីធីតាប្រមូលសំពត់ និងអាភរណៈដែលខ្លួនអាចកាន់យកបាន ស្លៀកសំពត់ចាស់ កណ្តៀតក្អមចេញអំពីផ្ទះតាំងពីព្រលឹម ធ្វើដូចជាទៅកាន់កំពង់ទឹកជាមួយនឹងពួកនាងទាសី ដល់ទីនោះហើយ បានឈរចាំដំណើរមករបស់នាយ

ព្រាន ។ ចំណែកនាយព្រាន ក៏បររទេះចេញទៅអំពីព្រលឹមដែរ ។ ចំណែកនាងក៏ដើរតាមក្រោយនាយព្រាននោះ ។ ព្រានកុក្កុដមិត្តឃើញនាងដើរតាមក្រោយខ្លួន ក៏សួរថា “ សូមទោស! ខ្ញុំមិនស្គាល់ថា នាងជាធីតារបស់អ្នកណា, ដូច្នេះនាងកុំមកតាមខ្ញុំអី” ។ នាងឆ្លើយថា លោកមិនបានហៅខ្ញុំមក, ខ្ញុំមកតាមធម្មតារបស់ខ្ញុំ, លោកនៅស្ងៀមហើយ គិតតែបររទេះរបស់ខ្លួនទៅ ។ នាយព្រានសួរនាងហើយ សួរទៀតលុះនាងនិយាយនឹងខ្លួនថា ការហាមសិរីដែលមកកាន់សំណាក់របស់ខ្លួនមិនសមគួរឡើយ។ ទើបដឹងថា ការដែលនាងមកនេះគឺមកដើម្បីខ្លួនដោយឥតសង្ស័យហើយ បានបីនាងឡើងកាន់រទេះបរតទៅទៀត ។

មាតាបិតារបស់នាងឲ្យមនុស្សស្វែងរកសព្វទីកន្លែងមិនឃើញ ក៏សំគាល់ថា នាងស្លាប់ហើយ ក៏ផ្តើមធ្វើភត្តដើម្បីអ្នកស្លាប់ (មតកៈភត្ត) ។ ព្រោះតែនៅរួមជាមួយនឹងនាយព្រាននោះនាងក៏ប្រសូតបានបុត្រ ៧ នាក់ដោយលំដាប់ ក្នុងកាលដែលបុត្រទាំងនោះចំរើនវ័យហើយ នាងបានចងបុត្រទាំងនោះដោយគ្រឿងគឺផ្ទះ ។

# កុក្កុដមិត្តចងអាឃាតនឹងព្រះសម្មាសម្ពុទ្ធ

ថ្ងៃមួយ ព្រះសាស្តាទ្រង់ប្រមើលមើលនូវសត្វលោកក្នុងវេលាជិតភ្លឺ ទ្រង់ឃើញនាយព្រានកុក្កុដមិត្ត ព្រមទាំងបុត្រនិងកូនប្រសារចូលទៅក្នុងសំណាញ់គឺព្រះ ញាណរបស់ព្រះអង្គ ទ្រង់ពិចារណាតទៅទៀតថា "តើមានហេតុអ្វីហ្ន៎" ទ្រង់ឃើញឧបនិស្ស័យនៃជនទាំងនោះហើយ ទ្រង់ប្រដាប់បាត្រនិងចីវរយាងទៅកាន់ទីដាក់អន្ទាក់របស់នាយព្រាននោះ តាំងអំពីព្រលឹម ៗ ថ្ងៃនោះ ម្រឹគសូម្បីតែមួយក៏មិនបានជាប់អន្ទាក់ ។

ព្រះសាស្តា ទ្រង់សំដែងស្នាមព្រះបាទទុក ជិតអន្ទាក់របស់ព្រានហើយ ទ្រង់គង់ក្រោមម្លប់ឈើមួយដើមខាងមុខ ។ នាយព្រានកុក្កុដមិត្តកាន់ធ្នូទៅកន្លែងអន្ទាក់អំពីព្រលឹម ហើយពិនិត្យមើលអន្ទាក់តាំងពីដើម មិនឃើញម្រឹគជាប់អន្ទាក់សូម្បីត្រឹមតែ ១ បានឃើញស្នាមព្រះបាទរបស់ព្រះសាស្តា ហើយក៏ត្រិះរិះដូច្នេះថា នរណាដើរស្រាយម្រឹគដែលជាប់អន្ទាក់របស់យើងអស់ ។ នាយព្រានចងអាឃាតនឹងព្រះសាស្តា ដើរទៅមុខបន្តិចក៏ឃើញព្រះសាស្តាដែលទ្រង់គង់ក្រោមដើមឈើគិតថា សមណៈនេះព្រលែងម្រឹគដែលជាប់អន្ទាក់របស់យើង,

យើងនឹងសម្លាប់សមណៈនេះ, រួចហើយក៏បានយឺតធ្នូតម្រង់ទៅរកព្រះសាស្តា ។ ព្រះសាស្តា ទ្រង់ឲ្យយឺតធ្នូបាន ប៉ុន្តែមិនទ្រង់ឲ្យព្រលែងធ្នូទៅបាន ។ នាយព្រានព្រលែងកូនសរទៅក៏បាន ដាក់ធ្នូចុះវិញក៏បាន មានអាការហាក់ដូចជាបែកឆ្អឹងជំនីទាំងពីរ មានទឹកមាត់ហូរចេញអំពីមាត់ ឈរនៅដោយលំបាកកាយ ។

គ្រានោះ ពួកបុត្ររបស់គាត់ទៅផ្ទះនិយាយគ្នាថា បិតារបស់យើងទៅជេញអីក៏យូរម៉្លេះ តើមានហេតុអ្វីហ្ន៎?, កាលមាតារបស់គេបញ្ជូនទៅពាក្យថា ម្នាលកូនទាំងឡាយ កូនឯងចូរទៅកាន់សំណាក់របស់បិតាកូនឯងមើល៍,ម្នាក់ៗក៏នាំគ្នាកាន់យកធ្នូចេញទៅឃើញបិតាឈរអាការដូច្នោះ ក៏គិតថា បុរសនេះប្រាកដជាបច្ចាមិត្តរបស់បិតាពួកយើង, ទាំង ៧ នាក់យឺតធ្នូតម្រង់ទៅរកព្រះសម្មាសម្ពុទ្ធ ក៏បានឈរទ្រឹងដូចបិតារបស់ពួកគេដែរ ដោយអានុភាពរបស់ព្រះសម្ពុទ្ធ ។

## ព្រានកុក្កុដមិត្តឈប់ចងអាឃាតនិងព្រះសម្ពុទ្ធ

គ្រានោះ មាតារបស់ពួកគេ គិតថា ព្រោះហេតុអ្វីហ្ន៎ បិតានិងបុត្រទៅយូរម៉្លេះ ក៏នាំកូនប្រសារ ៧ នាក់ទៅកាន់ទីនោះ

លុះទៅដល់ទីនោះឃើញជនទាំងនោះឈរសំកាំងដូច្នោះ គិតថា ជនទាំងនេះឈរឃើតផ្ចង់រកបុគ្គលណាហ្ន៎ ? ក្រឡេកទៅក៏ឃើញព្រះសាស្តា ទើបលើកដៃទាំងពីរស្រែកឡើងយ៉ាងខ្លាំងថា អ្នកទាំងឡាយកុំញ៉ាំងបិតារបស់យើងឲ្យវិនាសឡើយ, ពួកអ្នករាល់គ្នាកុំញ៉ាំងបិតារបស់យើងឲ្យវិនាស ។

នាយព្រានកុក្កុដមិត្ត បានឮសំឡេងនោះហើយ ក៏គិតថា យើងវិនាសហើយហ្ន៎ ព្រោះបុរសនោះជាឪពុកក្មេករបស់យើង, ស្លាប់ហើយយើង យើងបានធ្វើកម្មធ្ងន់ណាស់, សូម្បីពួកបុត្ររបស់គាត់ក៏គិតថា វិនាសហើយពួកយើង ព្រោះបុរសនោះជាជីតារបស់យើង ពួកយើងបានធ្វើកម្មធ្ងន់ណាស់ ។ នាយព្រានកុក្កុដមិត្តបានធ្វើមេត្តាចិត្តទុកថា អ្នកនេះជាឪ-ពុកក្មេករបស់យើង ។ សូម្បីពួកបុត្ររបស់គាត់ក៏ញ៉ាំងមេត្តាចិត្តឲ្យឡើងថា អ្នកនេះជាជីតារបស់ពួកយើង ។ គ្រានោះសេដ្ឋីធីតាដែលជាមាតារបស់ពួកគេបាននិយាយថា ពួកអ្នកបោះធ្នូចោលហើយ សូមទោសបិតារបស់ខ្ញុំដើម្បីឲ្យបិតារបស់ខ្ញុំអត់ទោសឲ្យផង ។

## ជនទាំងអស់នោះសម្រេចសោតាបត្តិផល

ព្រះសាស្តា ទ្រង់ជ្រាបថាចិត្តរបស់ជនទាំងនោះជាគុណជាតទោទន់ហើយ ទើបឲ្យដាក់ធ្នូចុះបាន ។ ជនទាំងអស់នោះថ្វាយបង្គំព្រះសាស្តាហើយ សូមឲ្យព្រះអង្គអត់ទោសឲ្យថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គអត់ទោសឲ្យខ្ញុំព្រះអង្គទាំងឡាយផង ដូច្នេះហើយ អង្គុយនៅទីដ៏សមគួរ ។ លំដាប់នោះព្រះសាស្តាត្រាស់អនុបុព្វីកថាដល់ពួកគេ ។ ក្នុងវេលាចប់ទេសនា នាយព្រានកុក្កុដមិត្តព្រមទាំងបុត្រនិងកូនប្រសារបានសម្រេចសោតាបត្តិផល ។ ព្រះសាស្តាត្រាច់ទៅបិណ្ឌបាតហើយ សម្រេចកត្តកិច្ចហើយស្តេចយាងទៅកាន់វិហារវិញ ។ គ្រានោះ ព្រះអានន្ទត្ថេរ ទូលសួរព្រះអង្គថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះ ព្រះអង្គស្តេចយាងទៅកាន់ទីណា ?

ព្រះសាស្តា. “ម្នាលអានន្ទ ថ្ងៃនេះ តថាគតទៅកាន់សំណាក់របស់កុក្កុដមិត្ត ។

អានន្ទ. បពិត្រព្រះអង្គដ៏ចំរើន នាយព្រានកុក្កុដមិត្តនោះត្រូវព្រះអង្គធ្វើឲ្យជាអ្នកឈប់ធ្វើកម្មគឺបាណាតិបាតហើយឬ ?

ព្រះសាស្តា. អើ អានន្ទ នាយព្រានកុក្កុដមិត្តនោះ មានខ្លួនជាគំរប់ ១៥ បានតាំងនៅក្នុងសទ្ធាដែលមិនញាប់ញ័រ ជា

អ្នកអស់សេចក្តីសង្ស័យក្នុងរតនៈ ៣ ជាអ្នកមិនធ្វើកម្មគឺបា-ណាតិបាតទៀតទេ ។

ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រាននោះមានកិរិយាមិនមែនឬ ? ព្រះសាស្តាត្រាស់ថា ពិតមែនហើយ ភិក្ខុទាំងឡាយ, នាងជាកុមារិកាក្នុងត្រកូលសេដ្ឋីម្នាក់បានសម្រេចសោតាបត្តិផលហើយ ។

## ព្រះសោតាបន្នមិនធ្វើបាប

ពួកភិក្ខុសន្ទនាគ្នាថា កិរិយារបស់នាយព្រានកុក្កុដមិត្តបានសម្រេចសោតាបត្តិផលក្នុងកាលដែលខ្លួននៅជាក្មេងតូចម៉្លេះ ហើយទៅកាន់ផ្ទះរបស់នាយព្រាននោះបានបុត្រ ៧ នាក់, ហើយនាងត្រូវស្វាមីប្រើអស់កាលប៉ុណ្ណោះថា នាងចូរនាំធ្នូមក នាំកូនសរមក នាំលំពែងមក នាំស្នមក យកអន្ទាក់មក, បានឲ្យវត្ថុទាំងនោះទៅព្រាន នាយព្រាននោះកាន់គ្រឿងប្រហារដែលនាងឲ្យហើយនោះទៅធ្វើបាណាតិបាត, សូម្បីព្រះសោតាបន្នទាំងឡាយក៏នៅតែធ្វើបាណាតិបាតដែរហ្ន៎ ។

ព្រះសាស្តាស្តេចយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ តើអ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាអំពីរឿង

អ្វី ? កាលភិក្ខុទាំងនោះក្រាបទូលថា អំពីរឿងឈ្មោះនេះ, ក៏ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រះសោតាបន្ន រមែងមិនធ្វើបាណាតិបាតឡើយ, ប៉ុន្តែការដែលនាងបានធ្វើដូច្នោះ ព្រោះបានគិតថា យើងនឹងធ្វើតាមពាក្យស្វាមី, ចិត្តរបស់នាងមិនមានបំណងចង់ឲ្យស្វាមីរបស់កាន់យកគ្រឿងប្រហារដែលហុចឲ្យទៅធ្វើបាណាតិបាតទេ,ពិតណាស់ កាលបាទដៃមិនមានដំបៅ ថ្នាំពិសក៏មិនអាចនឹងឲ្យទោសដល់អ្នកកាន់ថ្នាំពិសនោះបាន យ៉ាងណា, ដែលឈ្មោះថា បាប រមែងមិនមានដល់អ្នកមិនធ្វើបាប សូម្បីនាំគ្រឿងប្រហារទាំងឡាយមានធ្នូជាដើមចេញឲ្យ ព្រោះមិនមានអកុសលចេតនា ដូច្នោះដែរ ដូច្នេះហើយ កាលនឹងបន្តអនុសន្ធិដើម្បីសំដែងធម៌ ទើបត្រាស់ធម្មទេសនានេះថា ៖

**៨ បាណិម្ហិ ចេ វណោ នាស្ស ហរេយ្យ បាណិនា វិសំ**
**នាព្វណំ វិសមន្វេតិ នត្ថិ បាបំ អកុព្វតោ ។**

បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីនាំ
យកថ្នាំពិសដោយបាតដៃ ថ្នាំពិសតែងមិនជ្រាប
ចូលទៅកាន់បាតដៃដែលគ្មានដំបៅ យ៉ាងណា បាប

រមែងមិនមាន ដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះដែរ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **នាស្ស** ប្រែថា មិនមាន ។

បទថា **ហរេយ្យ** ប្រែថា អាចនាំទៅបាន ។

សួរថា ព្រោះហេតុអ្វី ព្រោះថា ថ្នាំពិសមិនអាចជ្រាបចូលទៅកាន់បាតដៃដែលមិនមានដំបៅទេ, ពិតណាស់ ថ្នាំពិស រមែងមិនជ្រួតជ្រាបទៅចូលកាន់បាតដៃដែលមិនមានដំបៅ យ៉ាងណា, ដែលឈ្មោះថា បាប ក៏រមែងមិនមានដល់អ្នកមិនធ្វើបាប សូម្បីនាំគ្រឿងប្រហារទាំងឡាយមានធ្នូជាដើមចេញឲ្យ ដូច្នោះដែរ, មែនពិត បាប រមែងមិនជាប់តាមចិត្តបុគ្គលនោះ ដូចថ្នាំពិសមិនជ្រាបចូលទៅកាន់បាតដៃដែលមិនមានដំបៅដូច្នោះ ដូច្នេះឯង ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

## បុព្វកម្មរបស់កុក្កុដមិត្តព្រមទាំងបុត្រនិងកូនប្រសារ

សម័យខាងក្រោយមក ពួកភិក្ខុសន្ទនាគ្នាថា សភាវៈអ្វីហ្ន៎ដែលជាឧបនិស្ស័យនៃសោតាបត្តិមគ្គ របស់នាយព្រាន

កុក្កុជមិត្តព្រមទាំងបុត្រនិងកូនប្រសារ ហើយសភាវៈអ្វីហ្ន៎ ដែលធ្វើឲ្យព្រាននេះកើតក្នុងត្រកូលព្រានម្រឹគ ?

ព្រះសាស្ដាស្ដេចមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយអង្គុយសន្ទនាគ្នាអំពីរឿងអ្វី ?" កាលភិក្ខុទាំងនោះក្រាបទូលថា អំពីរឿងឈ្មោះនេះ, ក៏ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាលជនទាំងឡាយចាត់ចែងកសាងចេតិយបញ្ចុះព្រះធាតុរបស់ព្រះកស្សបទសពល ក៏បានប្រឹក្សាគ្នាយ៉ាងនេះថា បានអ្វីធ្វើជាដីស្អិត បានអ្វីធ្វើជាទឹកនៃចេតិយនេះ ?"

## ការសាងចេតិយក្នុងសម័យមុន

គ្រានោះ ពួកជនទាំងនោះសម្រេចថា នឹងយកថ្មនោសិលាពណ៌លឿងធ្វើជាដីស្អិត យកប្រេងល្ងនឹងជាទឹក ។ ពួកគេបុកថ្មនោសិលានោះហើយ ផ្សំនឹងប្រេងល្ង កដោយឥដ្ឋដែលបិទដោយមាស ហើយច្នាក់ក្បាច់ខាងក្នុង ។ អំពីខាងក្រៅខាងមុខមានឥដ្ឋមាសទាំងដុំៗ ។ ឥដ្ឋមួយដុំៗមានតំលៃមួយសែន ។ លុះចេតិយសម្រេចហើយ ក៏ប្រឹក្សាគ្នាថា "ក្នុងកាលបញ្ចុះព្រះធាតុត្រូវការទ្រព្យច្រើន, តើពួកយើងនឹងលើក

បុគ្គលណាឲ្យធ្វើជាប្រធានហ្ន៎?” ។

## ដណ្ដើមគ្នាធ្វើជាប្រធានក្នុងការបញ្ចុះព្រះធាតុ

គ្រានោះ សេដ្ឋីជនបទម្នាក់ ពោលថា “ខ្ញុំនឹងធ្វើជាប្រធាន” លុះពោលដូច្នេះហើយ ក៏បានដាក់ប្រាក់មួយកោដិក្នុងទីបញ្ចុះព្រះសារីរិកធាតុ ពួកអ្នកនគរតិះដៀលសេដ្ឋីក្នុងក្រុងថា “សេដ្ឋីនេះគិតតែពីប្រមូលទ្រព្យទុក, មិនអាចជាប្រធានក្នុងព្រះចេតិយនេះបានទេ ចំណែកសេដ្ឋីជនបទ ដាក់ទ្រព្យមួយកោដិ ទើបសមធ្វើជាប្រធាន” ។

សេដ្ឋីក្នុងក្រុងនោះ បានឮពាក្យរបស់ជនទាំងនោះហើយ ពោលថា “យើងនឹងធ្វើជាប្រធាន” លុះពោលដូច្នេះហើយ ក៏បានដាក់ទ្រព្យពីរកោដិទៅក្នុងទីបញ្ចុះព្រះសារីរិកធាតុ ។

សេដ្ឋីជនបទ គិតថា “យើងនឹងធ្វើជាប្រធាន” រួចក៏បានឲ្យទ្រព្យបីកោដិ ។ កាលសេដ្ឋីទាំងពីរនាក់នោះបង្កើនទ្រព្យដោយអាការយ៉ាងនោះ, សេដ្ឋីក្នុងក្រុងបានឲ្យទ្រព្យ ៨ កោដិ ។ ព្រោះដូច្នោះ ទើបសេដ្ឋីជនបទគិតថា “ប្រសិនបើយើងឲ្យទ្រព្យ ៩ កោដិសោត, សេដ្ឋីនេះនឹងពោលថា យើងនឹងឲ្យ ១០ កោដិ” ។ កាលបើដូច្នោះ ទ្រព្យរបស់យើងនឹង

អស់ទៅជាប្រាកដ” ទើបគាត់ពោលយ៉ាងនេះថា “យើងនឹងឲ្យទ្រព្យប្រមាណប៉ុណ្ណេះ, ហើយសូមធ្វើជាទាសៈរបស់ចេតិយទាំងអស់គ្នា លុះដូច្នេះហើយក៏នាំបុត្រទាំង ៧ នាក់ កូនប្រសារទាំង ៧ នាក់និងភរិយាទៅប្រគល់ចំពោះព្រះចេតិយព្រមជាមួយនឹងខ្លួន ។

## សេដ្ឋីជនបទបានធ្វើជាប្រធាន

ពួកអ្នកនគរលើកសេដ្ឋីដែលមានប្រក្រតីនៅក្នុងជនបទនោះឲ្យធ្វើជាប្រធាន ដោយអាងថា “ដែលឈ្មោះថា ទ្រព្យសម្បត្តិ នរណាៗក៏អាចស្វែងរកបានដែរ, ប៉ុន្តែសេដ្ឋីជនបទនេះព្រមទាំងបុត្រនិងភរិយា បានប្រគល់ខ្លួនចំពោះចេតិយ, សេដ្ឋីនេះឯង ចូរធ្វើជាប្រធានចុះ” ។ ជនទាំង ១៦ នាក់បានធ្វើជាទាសៈរបស់ចេតិយដោយប្រការដូច្នេះ ។ ប៉ុន្តែពួកអ្នកនគរបានធ្វើពួកគាត់ឲ្យជាអ្នកជា ។ សូម្បីបានទៅជាអ្នកជាហើយក៏ដោយ ពួកគាត់នៅតែបដិបត្តិចេតិយរហូតអស់អាយុ ចុតិចាកអត្តភាពនោះហើយ បដិសន្ធិក្នុងទេវលោក ។ កាលជនទាំងនោះ នៅក្នុងទេវលោកអស់មួយពុទ្ធន្តរហើយ ក្នុងពុទ្ធុប្បាទនេះ ភរិយារបស់សេដ្ឋីនោះចុតិចាកទេវលោក

ហើយ បដិសន្ធិជាធីតាសេដ្ឋីក្នុងក្រុងរាជគ្រឹះ ។

## គតិរបស់អ្នកមិនឃើញសច្ចៈមិនទៀងទាត់

នាងបានសម្រេចសោតាបត្តិផល តាំងពីនៅជាកុមារិកាម៉្លេះ ។ ដែលឈ្មោះថា បដិសន្ធិរបស់សត្វដែលមិនបានឃើញសច្ចៈជាការៈដ៏ធ្ងន់ ព្រោះហេតុដូច្នោះ ទើបស្វាមីរបស់នាងវិលត្រឡប់ទៅកើតក្នុងត្រកូលព្រានម្រឹគ ។ សេចក្ដីស្នេហាក្នុងកាលមុនបានគ្របសង្កត់ធីតារបស់សេដ្ឋីព្រមគ្នានឹងការឃើញនាយព្រានកុក្កុដមិត្តនោះឯង ។ ពិតណាស់ សូម្បីព្រះមានព្រះភាគ ក៏បានត្រាស់ពាក្យនេះទុកថា ៖

សេចក្ដីស្រឡាញ់ រមែងកើតឡើង ព្រោះ
អាស្រ័យហេតុ ២ ប្រការ គឺព្រោះការនៅ
រួមគ្នាក្នុងកាលមុន ១ ដោយការប្រព្រឹត្ត
នូវអំពើជាប្រយោជន៍ដល់គ្នានឹងគ្នាក្នុងបច្ចុប្បន្ន ១
ដូចផ្កាឈូកកើតក្នុងទឹក ( ព្រោះអាស្រ័យភក់
និងទឹក ) ដូច្នោះ ។

ធីតារបស់សេដ្ឋីនោះ បានទៅកាន់ត្រកូលរបស់ព្រានម្រឹគ ព្រោះសេចក្ដីស្នេហាក្នុងកាលមុន, សូម្បីពួកបុត្ររបស់

នាង ក៏ចុតិចាកទេវលោក មកបដិសន្ធិក្នុងផ្ទៃរបស់នាងដែរ ។

សូម្បីកូនប្រសាររបស់នាង ក៏កើតក្នុងទីនោះៗ លុះចំរើនវ័យហើយ បានធ្វើជាកូនប្រសាររបស់នាង ។ ជនទាំងអស់នោះ បដិបត្តិចេតិយក្នុងកាលនោះ ដោយប្រការដូច្នេះហើយ ទើបបានសម្រេចសោតាបត្តិផល ដោយអានុភាពនៃកម្ម នោះដូច្នេះឯង ។

( រឿងនាយព្រានកុក្កុដមិត្ត ចប់ )

********************

## ៩. រឿងនាយព្រានសុនខឈ្មោះកោកៈ

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាយព្រានសុនខឈ្មោះកោកៈ ត្រាស់ព្រះធម្មទេសនានេះថា *"យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ"* ជាដើម ។

### នាយព្រានជួបព្រះថេរៈត្រាច់បិណ្ឌបាត

បានឮថា ក្នុងបុព្វណ្ហសម័យនាថ្ងៃមួយ នាយព្រាននោះកាន់ធ្នូ ហើយមានសុនខចោមរោមចេញទៅព្រៃបានជួបភិក្ខុអ្នកមានកិរិយាព្រឹត្តបិណ្ឌបាតជាវត្តមួយរូប កំពុងតែត្រាច់បិណ្ឌបាតក្នុងចន្លោះនៃផ្លូវ ក្រោធហើយ គិតថា យើងបានជួបមនុស្សកាឡកណ្ណិ, ថ្ងៃនេះនឹងមិនបានអ្វីៗឡើយ ហើយក៏ចៀសចេញទៅ ។ ចំណែកព្រះថេរៈ ត្រាច់ទៅបិណ្ឌបាតក្នុងភូមិស្រុក ធ្វើភត្តកិច្ចហើយ ក៏ត្រឡប់ទៅកាន់វិហារវិញ ។

### នាយព្រានឲ្យសុនខខាំព្រះថេរៈ

ចំណែកព្រានរូបនោះ ទៅព្រៃមិនបានអ្វីៗសោះ ក៏ត្រឡប់មកវិញ បានជួបព្រះថេរៈម្ដងទៀត ទើបគិតថា ថ្ងៃនេះ

ព្រោះតែយើងបានជួបមនុស្សកោឡកណ្ណិនេះហើយ ទើបយើងទៅព្រៃមិនបានអ្វីសោះ ឥឡូវនេះ លោកបានមកប្រាកដចំពោះមុខអញម្តងទៀត, យើងនឹងឲ្យសុនខទាំងឡាយខាំកិក្ខុរូបនេះឲ្យស្លាប់ រួចហើយក៏ឲ្យសញ្ញាលែងសុនខទៅ ។ ព្រះថេរៈអង្វរថា "ម្នាលឧបាសក លោកកុំធ្វើដូច្នេះឡើយ" ។ ព្រានកំហូចនោះស្រែកប្រាប់ព្រះថេរៈថា "ថ្ងៃនេះ យើងមិនបានទូវអ្វីៗ ព្រោះតែបានជួបលោក, ហើយឥឡូវនេះ លោកក៏មកជួបយើងម្តងទៀត, យើងនឹងឲ្យសុនខខាំលោកឲ្យស្លាប់, រួចហើយពន្យុះសុនខឲ្យដេញខាំព្រះថេរៈ ។ ព្រះថេរៈបានឡើងដើមឈើមួយដើមយ៉ាងរហ័ស គង់នៅត្រង់ទីខ្ពស់មួយជួរបុរស ។ សុនខទាំងឡាយ ក៏នាំគ្នាចោមរោមដើមឈើនោះ ។

## នាយព្រានចាក់ព្រះថេរៈ

នាយកោកៈនោះទៅដល់ទីនោះហើយស្រែកប្រាប់ព្រះ ថេរៈថាសូម្បីលោកឯងឡើងដើមឈើក៏មិនផុតអំពីកណ្តាប់ដៃ
របស់យើងដែរ លុះពោលដូច្នេះហើយក៏ចាក់បាតជើងព្រះថេរៈដោយចុងព្រួញ ។ ព្រះថេរៈបានត្រឹមតែអង្វរថា "ម្នាលឧបាសក សូមអ្នកកុំធ្វើដូច្នេះឡើយ ។ នាយកោកៈរូបនោះ

មិនបានអើពើនឹងពាក្យអង្វររបស់ព្រះថេរៈឡើយ ខំប្រឹងតែចាក់ខ្លាំងឡើងៗ ។ ចំណែកព្រះថេរៈ កាលត្រូវព្រាន ចាក់បាតជើងម្ខាង ក៏លើកជើងម្ខាងនោះឡើង ទំលាក់ជើងម្ខាងទៀតចុះ កាលព្រានចាក់ជើងម្ខាងនោះទៀត ក៏លើកជើងនោះឡើងវិញ, នាយកោកៈមិនស្តាប់ពាក្យអង្វរកររបស់ព្រះថេរៈឡើយ ចាក់បាតជើងទាំងពីររបស់ព្រះថេរៈ ដោយអាការយ៉ាងនេះឯង ។ សរីរៈរបស់ព្រះថេរៈដូចជាត្រូវឆេះរោលដោយគប់ភ្លើង ។ ដោយសារតែទុក្ខវេទនាគ្របសង្កត់ខ្លាំងពេកទើបលោកមិនអាចគ្រប់គ្រងសតិបាន, សូម្បីចីវរដែលលោកដណ្តប់របូតធ្លាក់ចុះក៏មិនដឹង ។ ចីវរនោះធ្លាក់ចុះទៅគ្របនាយកោកៈនោះតាំងអំពីក្បាល ។

## ហ្វូងសុនខចោមរោមខាំនាយព្រាន

ហ្វូងសុនខនាំគ្នាចូលទៅក្នុងចន្លោះនៃចីវរ ដោយសំគាល់ថា ព្រះថេរៈធ្លាក់ចុះមក ហើយក៏នាំគ្នាខាំម្ចាស់របស់ខ្លួនអង្កៀមស៊ីបន្សល់ទុកតែឆ្អឹង ។ សុនខទាំងឡាយចេញមកអំពីចន្លោះនៃចីវរហើយ ឈរនៅខាងក្រៅ ។ ខណៈនោះ ព្រះថេរៈកាច់មែកឈើស្ងួតមួយ គ្រវែងបន្ទើលសុនខទាំងនោះ ។

ហ្វូងសុនខឃើញព្រះថេរៈហើយ ដឹងថា ពួកខ្លួនខាំស៊ីម្ចាស់របស់ខ្លួនឯង ក៏នាំគ្នាបោលចូលព្រៃ ។

## ព្រះថេរៈសង្ស័យក្នុងសីលនិងសមណភាពរបស់ខ្លួន

ព្រះថេរៈកើតការសង្ស័យឡើងថា បុរសនោះដល់នូវការវិនាសខ្លួន ព្រោះតែចូលមកកាន់ចន្លោះនៃចីវររបស់យើង , សីលរបស់យើងមិនដាច់ទេឬ លោកចុះពីដើមឈើហើយ ទៅកាន់សំណាក់របស់ព្រះសាស្តា ក្រាបទូលរឿងរ៉ាវទាំងអស់នោះតាំងពីដើម ហើយទូលសួរថា "បពិត្រព្រះអង្គដ៏ចំរើន ឧបាសកនោះវិនាសខ្លួន ព្រោះអាស្រ័យចីវររបស់ខ្ញុំព្រះអង្គ , សីលរបស់ខ្ញុំព្រះអង្គមិនដាច់ធ្លុះធ្លាយទេឬ? សមណភាពរបស់ខ្ញុំព្រះអង្គនៅមានដែរឬ ?"

## ព្រះសាស្តាធានាសីលនិងសមណភាព

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ព្រះថេរៈនោះហើយ ត្រាស់ថា "ម្នាលភិក្ខុ សីលរបស់អ្នកមិនដាច់ទេ, សមណភាពរបស់អ្នកនៅមាន, បុរសនោះប្រទូសរ៉ាយចំពោះអ្នកដែលជាអ្នកមិនប្រទូសរ៉ាយ ទើបដល់នូវសេចក្តីវិនាសយ៉ាងនេះ, ហើយបុរសនោះមិនមែនទើបតែប្រទុស្តរ៉ាយចំពោះ

អ្នកក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ, សូម្បីក្នុងអតីតកាល ក៏ធ្លាប់ប្រទូសរ៉ាយចំពោះអ្នកដែលមិនប្រទូសរ៉ាយ ដល់នូវសេចក្ដីវិនាសដែរ ដូច្នេះហើយ កាលនឹងទ្រង់ប្រកាសនូវរឿងនោះ ទើបទ្រង់នាំអតីតនិទានមកត្រាស់ដូច្នេះថា

## បុព្វកម្មរបស់នាយព្រាន

បានឮមកថា ក្នុងអតីតកាល មានពេទ្យម្នាក់ត្រាច់ទៅកាន់ភូមិស្រុកដើម្បីមើលជម្ងឺ មិនបាននូវកម្មអ្វីៗ ត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ ក៏ចេញមកវិញ បានជួបក្មេងៗជាច្រើនកំពុងតែលេងនៅក្បែរទ្វារស្រុក គិតថា យើងនឹងឲ្យពស់ចឹកក្មេងទាំងនេះ ហើយរក្សា ( ព្យាបាល ) នឹងបានអាហារបរិភោគ, ដូច្នេះហើយ ក៏បង្ហាញពស់ដែលដេកលៀនក្បាលចេញមកក្នុងរន្ធឈើមួយ ប្រាប់ថា នែពួកក្មេងដ៏ចំរើនទាំងឡាយ នុ៎ះកូនសារិកា ពួកឯងចូរចាប់វាមក ។

គ្រានោះ ក្មេងម្នាក់ចាប់ពស់ត្រង់ក.យ៉ាងមាំទាញចេញមក ដឹងថា វាជាពស់ ក៏ស្រែកឡើងហើយ បោះគ្រវែងពស់នោះទៅលើក្បាលពេទ្យដែលឈរនៅជិតនោះ ។ ពស់រិតរុំបំពង់ក.របស់ពេទ្យ ចឹកយ៉ាងដំណាំឲ្យក្ស័យជីវិតក្នុងទីនោះ

ឯង ។ នាយកោកៈព្រានសុនខនោះ សូម្បីក្នុងកាលមុន ក៏ប្រទូសរ៉ាយចំពោះអ្នកដែលមិនប្រទូសរ៉ាយ ដល់នូវសេចក្ដីវិនាសយ៉ាងនោះដែរ ។

ព្រះសាស្ដា លុះទ្រង់នាំអតីតនិទាននេះមកហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសំដែងធម៌ បានត្រាស់គាថានេះថា ៖

**៩ យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ**
**សុទ្ធស្ស បោសស្ស អនង្គណស្ស**
**តមេវ ពាលំ បច្ចេតិ បាបំ**
**សុខុមោ រជោ បដិវាតំវ ខិត្តោ ។**

បុគ្គលណាប្រទូស្ដ ចំពោះអ្នកមិនប្រទូស្ដតប
ជាសត្វស្អាត មិនមានកិលេស ដូចជាទីទួល បាប
រមែងត្រឡប់មករកបុគ្គលពាលនោះវិញ ដូចធូលី
ល្អិត ដែលបុគ្គលបាចទៅកាន់ទីច្រាស់ខ្យល់ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អប្បទុដ្ឋស្ស** គឺអ្នកមិនប្រទូស្ដរ៉ាយចំពោះខ្លួនឯង ឬចំពោះសព្វសត្វ ។

បទថា **នរស្ស** បានដល់ សត្វ ។

បទថា **ទុស្សតិ** ប្រែថា រមែងប្រព្រឹត្តខុស ។ បទថា **សុទ្ធស្ស** គឺអ្នកមិនមានកំហុស ។ សូម្បីពាក្យថា **បោសស្ស** នេះ ក៏ជាឈ្មោះរបស់សត្វនោះឯង ។ បទ ថា **អនង្គណស្ស** គឺអ្នកមិនមានកិលេស ។ ពាក្យថា **បច្ចេតិ** កាត់បទជា **បដិ + ឯតិ** ( ប្រែថា រមែងត្រឡប់មករក ) ។

បទថា **បដិវាតំ** ជាដើម សេចក្តីថា ធូលីដ៏ល្អិត ដែលបុរសម្នាក់បាចទៅ ដោយបំណងប្រហារមនុស្សម្នាក់ ដែលឈរនៅក្នុងទីច្រាស់ខ្យល់ រមែងត្រឡប់មករកបុរសនោះវិញ គឺធ្លាក់មកលើបុគ្គលអ្នកបាចនោះឯង យ៉ាងណា, បុគ្គលណាកាលប្រហារដោយបាតដៃជាដើម ឈ្មោះថា រមែងប្រទូស្តរ៉ាយចំពោះបុរសអ្នកមិនប្រទូសរ៉ាយតប, បាបនោះកាលឲ្យផលក្នុងបច្ចុប្បន្ននេះ ឬក្នុងអបាយទាំងឡាយមាននរកជាដើមក្នុងកាលខាងមុខ ឈ្មោះថា រមែងត្រឡប់មករកបុគ្គលពាលនោះវិញ ដោយអំណាចវិបាកទុក្ខដូច្នេះដែរ ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះតាំងនៅក្នុងព្រះអរហត្តផល ។ ព្រះធម្មទេសនា បានជាកថាមានប្រយោជន៍ដល់បរិស័ទដែលមកប្រជុំគ្នានៅទីនោះ។

( រឿងនាយព្រានសុនខឈ្មោះកោកៈ ចប់ )

********************

# ១០. រឿងព្រះតិស្សត្ថេរចូលទៅកាន់ត្រកូលជាងកែវមណី

## *សេចក្ដីខាងដើម*

*ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះតិស្សៈ អ្នកចូលទៅកាន់ត្រកូលជាងកែវមណី ត្រាស់ព្រះធម្មទេសនានេះថា “**គព្ភមេកេ ឧប្បជ្ជន្តិ**” ជាដើម ។*

## *ព្រះបាទបសេនទិកោសលបញ្ជូនកែវមណី មកឲ្យជាងកែវច្នៃ*

*បានឮថា ព្រះថេរៈនោះ ឆាន់នៅក្នុងត្រកូលរបស់ជាងកែវមណីនោះអស់ ១២ ឆ្នាំ ។ ជាងកែវមណីនិងភរិយារបស់គាត់តាំងនៅក្នុងឋានៈដូចមាតានិងបិតារបស់ព្រះថេរៈ ទំនុកបំរុងព្រះថេរៈដោយសេចក្ដីគោរព ។*

*ថ្ងៃមួយ ជាងកែវមណីកំពុងអង្គុយហាន់សាច់ខាងមុខព្រះថេរៈ ។ លំដាប់នោះ ព្រះបាទបសេនទិកោសលទ្រង់បញ្ជូនកែវមណីមួយទៅដោយព្រះរាជបញ្ជាថា “ជាងកែវមណីចូរខាត់និងច្នៃកែវមណីនេះឲ្យល្អហើយបញ្ជូនមកឲ្យយើងវិញ។ ជាងកែវមណី ទទួលយកកែវនោះ ដោយដៃប្រឡាក់ឈាម*

យកមកដាក់លើជ្រញ់ហើយ ក៏ចូលទៅខាងក្នុងដើម្បីលាងដៃ។

## កែវមណីបាត់ជាងស៊ើបរកមនុស្សអ្នកយក

ក៏ក្នុងផ្ទះនោះ មានចិញ្ចឹមសត្វក្រៀលមួយ ។ ក្នុងកាលដែលព្រះថេរៈកំពុងតែក្រឡេកមើលនូវកែវមណីនោះ សត្វក្រៀលនោះក៏បានលេបនូវកែវមណីនោះដោយសំគាល់ថាជាដុំសាច់ ព្រោះជុំក្លិនឈាម ។ ជាងកែវមណីមកហើយ មិនឃើញកែវមណី ក៏សួរភរិយា ពីតានិងបុត្រដោយលំដាប់ថាអ្នកទាំងឡាយយកកែវមណីឬ ? កាលជនទាំងនោះឆ្លើយថាមិនបានយកទេ ក៏គិតថា ប្រាកដជាព្រះថេរៈកាន់យកហើយ ទើបប្រឹក្សានឹងភរិយាថា កែវមណីប្រាកដជាព្រះថេរៈជាអ្នកយក, ភរិយារបស់គាត់ប្រាប់ថា "បពិត្រស្វាមី អ្នកកុំពោលដូច្នោះឡើយ, រហូតអស់កាលប្រមាណប៉ុណ្ណោះ នាងខ្ញុំមិនធ្លាប់បានឃើញទោសអ្វីៗរបស់ព្រះថេរៈឡើយ, ព្រះថេរៈពិតជាមិនបានកាន់យកឡើយ ។ ជាងកែវមណីសួរព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់យកកែវមណីដែលខ្ញុំព្រះករុណាដាក់នៅទីនេះឬ ?"

ព្រះថេរៈ. ម្នាលឧបាសក អាត្មាភាពមិនបានកាន់យក

ទេ ជាងកែវមណី. លោកម្ចាស់ នៅទីនេះមិនមានមនុស្ស ដទៃទៀតទេ, ដូច្នោះមានតែលោកម្ចាស់ហ្នឹងហើយជាអ្នកយក នោះ, សូមលោកម្ចាស់ឲ្យកែវមណីមកខ្ញុំព្រះករុណាវិញ ។

កាលព្រះថេរៈបដិសេធ ទើបគាត់និយាយនឹងករិយាថា កែវរបស់យើងពិតជាព្រះថេរៈជាអ្នកយក, យើងនឹងគាបសួរ លោក ។

ករិយារបស់គាត់អង្វរថា បពិត្រស្វាមី អ្នកកុំញ៉ាំង យើងទាំងឡាយឲ្យវិនាសឡើយ ការដែលពួកយើងចូលដល់ ភាពជាទាសៈប្រសើរជាង, ឯការពោលទៅកាន់ព្រះថេរៈបែប នេះមិនប្រសើរសោះឡើយ ។

## ជាងកែវមណីធ្វើទោសព្រះថេរៈព្រោះយល់ខុស

ជាងកែវមណីនោះពោលថា ពួកយើងទាំងអស់គ្នា សូម្បីចូលដល់ភាពជាទាសៈ ក៏នៅតែមិនស្មើនឹងតំលៃនៃកែវ មណីនេះដែរ, លុះពោលដូច្នេះហើយ ក៏បានយកខ្សែរុំស្រោក់ នូវសីសៈរបស់ព្រះថេរៈ មួលរឹតដោយកំណាត់ឈើ ។ លោ ហិតហូរចេញអំពីសីសៈ ត្រចៀក និងច្រមុះរបស់ព្រះថេរៈ, គ្រាប់ភ្នែកទាំងពីរលៀនចេញមកក្រៅ,

លោកឈើចាប់ខ្ចាំងពេក ក៏ដួលចុះលើផែនដី ។ ក្រៀលនោះធុំក្លិនឈាម ក៏បានមកផឹកឈាមនោះ ។

## ជាងកែវមណីទាត់ក្រៀលស្លាប់ហើយទើបដឹងការពិត

គ្រានោះ ជាងកែវមណីបានទាត់សត្វក្រៀលមួយជើងហើយ គៀសចេញដោយពោលពាក្យថា ឯងមកធ្វើអ្វី ដោយកំឡាំងសេចក្តីក្រោធ ដែលកើតឡើងចំពោះព្រះថេរៈ ។ សត្វក្រៀលនោះដួលប្រកាច់ស្លាប់ ដោយការទាត់តែមួយជើងប៉ុណ្ណោះ ។ ព្រះថេរៈឃើញនូវអាការៈរបស់ក្រៀលនោះហើយក៏ពោលថា ម្នាលឧបាសក លោកចូរបន្ធូរនូវចំណងសីសៈរបស់អាត្មាឲ្យធូរសិនហើយ ចូរមិលមើលនូវសត្វក្រៀលនេះថា វាស្លាប់ហើយឬនៅ ? លំដាប់នោះ ជាងកែវមណីពោលនឹងព្រះថេរៈថា សូម្បីលោកឯងក៏នឹងស្លាប់ដូចវាដែរ ។

ព្រះថេរៈប្រាប់ជាងកែវមណីថា ម្នាលឧបាសក កែវមណីនោះគឺក្រៀលនេះឯងជាអ្នកលេប, ប្រសិនបើក្រៀលនេះមិនស្លាប់ទេ សូម្បីអាត្មាស្លាប់ ក៏មិនប្រាប់ដល់លោកដែរ ។

## ជាងកែវមណីបានកែវមណីមកវិញ

## ហើយសូមខមាទោសព្រះតិស្សត្ថេរ

គាត់យកសត្វក្រៀលនោះទៅវិះ បានឃើញកែវមណី ហើយ ញ័ររន្ធត់ មានចិត្តស្លុត ក្រាបចុះទៀបព្រះបាទរបស់ព្រះថេរៈ ហើយពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណាផង ខ្ញុំព្រះករុណាបានធ្វើនូវអំពើដោយការមិនដឹង ។

ព្រះថេរៈ. ម្នាលឧបាសក ទោសរបស់លោកក៏មិនមាន, ទោសរបស់អាត្មាក៏មិនមានដែរ, មានតែទោសរបស់វដ្តៈប៉ុណ្ណោះ , អាត្មាភាពអត់ទោសឲ្យ ។

ជាងកែវមណី. បពិត្រលោកម្ចាស់ដ៏ចម្រើន ប្រសិនបើលោកម្ចាស់ព្រមអត់ទោសឲ្យខ្ញុំព្រះករុណា សូមលោកម្ចាស់និមន្តទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំព្រះករុណាដូចដើមចុះ ។

## ព្រះថេរៈឃើញទោសនៃការចូលកាន់ត្រកូល

ព្រះថេរៈពោលថា ម្នាលឧបាសក តាំងអំពីថ្ងៃនេះទៅអាត្មាភាពនឹងមិនចូលកាន់ត្រកូលទៀតទេ ព្រោះថា នេះជាទោសនៃការចូលកាន់ត្រកូលដោយត្រង់, តាំងពីពេលនេះទៅបើជើងទាំងពីរនៅដើរបាន អាត្មានឹងឈរក្បែរទ្វារផ្ទះតែម្យ៉ាង

ទទួលភិក្ខា លុះពោលដូច្នេះហើយ ព្រះថេរៈក៏បានសមាទាន ធុតង្គ ហើយពោលគាថានេះថា ៖

កត្តុគ្រប់ៗ ត្រកូល បន្តិចបន្តួច ( មួយចានៗ ) ដែល
គេចំអិនទុកដើម្បីមុនី អាត្មានឹងត្រាច់ទៅដោយកំឡាំង
ស្មង, ( ព្រោះ ) កំឡាំងស្មងរបស់អាត្មានៅមាន ។

ព្រះថេរៈ លុះពោលគាថានេះចប់ហើយ មិនយូរប៉ុន្មាន ក៏បរិនិព្វានដោយព្យាធិនុ៎ះឯង ។

## មនុស្សធ្វើបាបនិងមនុស្សធ្វើបុណ្យមានគតិផ្សេងគ្នា

សត្វក្រៀល បានចាប់បដិសន្ធិ ក្នុងផ្ទៃនៃភរិយារបស់ ជាងកែវមណី ។ ជាងកែវមណីស្លាប់ទៅហើយ ក៏ទៅកើត ក្នុងនរក ។ ភរិយារបស់ជាងកែវមណីស្លាប់ទៅហើយ កើតក្នុង ទេវលោក ព្រោះជាអ្នកមានចិត្តទន់ភ្លន់ ចំពោះព្រះថេរៈ ។

ភិក្ខុទាំងឡាយទូលសួរអភិសម្បរាយភព របស់ជនទាំង នោះចំពោះព្រះសាស្តា ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះ ក្នុងលោកនេះ រមែងកើតក្នុងគភ៌, ពួកខ្លះ ធ្វើកម្មអាក្រក់ រមែង កើតក្នុងនរក, ពួកខ្លះ ធ្វើកម្មល្អហើយ រមែងកើតក្នុងទេវ-

លោក, ចំណែកអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

១០ គព្ភមេកេ ឧប្បជ្ជន្តិ   និរយំ បាបកម្មិនោ
សគ្គំ សុគតិនោ យន្តិ   បរិនិព្វន្តិ អនាសវា ។

ជនពួកខ្លះ កើតក្នុងគភ៌មនុស្ស ពួកអ្នកធ្វើអំពើអាក្រក់ ទៅកាន់នរក ពួកអ្នកមានគតិល្អ ទៅកាន់ស្ថានសួគ៌ ពួកអ្នកមិនមានអាសវៈ បរិនិព្វាន ។

## អធិប្បាយគាថា

ក្នុងបទទាំងនោះ គភ៌នៃមនុស្សប៉ុណ្ណោះ ព្រះសាស្ដាទ្រង់ប្រាថ្នាយកក្នុងបទថា **គព្ភំ** នេះ ។ ពាក្យដ៏សេសក្នុងគាថានេះ មានអតដ៏ងាយមែនពិត ។

ក្នុងកាលចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

( រឿងព្រះតិស្សត្ថេរអ្នកចូលទៅកាន់ត្រកូលជាងកែវមណី ចប់ )

***********************************

# ១១. រឿងជន ៣ នាក់

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធជន ៣ នាក់ ត្រាស់ព្រះធម្មទេសនានេះថា “**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**” ជាដើម ។

## ក្អែកត្រូវភ្លើងឆេះស្លាប់ក្នុងអាកាស

បានឮថា កាលព្រះសាស្ដាគង់នៅក្នុងវត្តជេតពន ភិក្ខុច្រើនរូបមកដើម្បីគាល់ព្រះសាស្ដា បានចូលទៅកាន់ស្រុកមួយដើម្បីបិណ្ឌបាត ។ ពួកអ្នកស្រុកទទួលបាត្ររបស់ភិក្ខុទាំងនោះហើយ និមន្តឲ្យគង់ក្នុងរោងឆាន់ ប្រគេនយាគូនិងបង្អែមឲ្យភិក្ខុទាំងនោះឆាន់ហើយ អង្គុយស្ដាប់ព្រះធម៌ដើម្បីរង់ចាំនូវភត្តកាល ។ ក្នុងខណៈនោះ អណ្ដាតភ្លើងតាំងឡើងអំពីចង្ក្រានរបស់ស្ត្រីម្នាក់ដែលចំអិនភត្ត ហើយចំអិនម្ហូបទឹកនិងម្ហូបក្រៀម ឆាបឆេះនូវជំបូល ។ រង្វេលថ្នាំងដែលធ្វើអំពីស្មៅមួយតាំងឡើងអំពីជំបូលនោះ ត្រូវភ្លើងឆេះអណ្ដែតឡើងទៅកាន់អាកាស ។ ក្នុងខណៈនោះឯង មានក្អែកមួយហើរមក

តាមអាកាស សិកកចូលទៅក្នុងរន្ធេលធ្នាំងនោះ ត្រូវស្មោនឹង វល្លិរុំពទ្ធដេះធ្លាក់ចុះមកចំកណ្ដាលស្រុក, ពួកភិក្ខុឃើញនូវហេតុនោះហើយ គិតថា ឱ ! កម្មនេះធ្ងន់ណាស់, ម្នាលអ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយ ចូរមើលនូវអាការដ៏ប្លែករបស់ក្អែកនោះចុះ, វៀរចាកព្រះសាស្ដាហើយ អ្នកដទៃណាហ្ន៎ នឹងដឹងនូវកម្មដែលក្អែកនេះបានធ្វើហើយ, ពួកយើងនឹងទូលសួរកម្មរបស់ក្អែកនោះចំពោះព្រះសាស្ដា ។

## កិរិយារបស់នាយសំពៅត្រូវទំលាក់ទឹក

ភិក្ខុមួយពួកទៀត ឡើងកាន់សំពៅទៅដើម្បីគាល់ព្រះសាស្ដា សំពៅនោះគៀងនៅកណ្ដាលសមុទ្រ ពួកមនុស្សដែលជិះនៅក្នុងសំពៅនោះ ប្រឹក្សាគ្នាថា ប្រហែលជាមានមនុស្សកាឡកណ្ណីនៅក្នុងសំពៅនេះទេដឹង? លុះប្រឹក្សាគ្នាដូច្នេះហើយ ក៏ចែកស្លាកឲ្យចាប់ ។ ក៏កិរិយារបស់នាយសំពៅនោះ តាំងនៅក្នុងបឋមវ័យ ជាស្រ្ដីមានរូបល្អគួរដល់ការមើល ចាប់បានស្លាកកាឡកណ្ណីនោះ ។ ពួកមនុស្សដែលជិះនៅក្នុងសំពៅនោះនាំគ្នា ពោលថា ចូរចែកស្លាកម្ដងទៀត ហើយឲ្យចែកដល់ទៅ ៣ ដង ។

ស្លាកបានធ្លាក់ទៅលើកិរិយារបស់នាយសំពៅនោះ ដល់ទៅ ៣ ដង ។ អ្នកដែលជិះនៅក្នុងសំពៅនោះបានក្រឡេក មើលមុខនាយសំពៅ ដោយពោលថា យ៉ាងម៉េច នាយ ? នាយសំពៅពោលថា ខ្ញុំមិនអាចឲ្យមហាជនវិនាស ព្រោះ តែនាងនេះទេ, ពួកលោកចូរបោះនាងទៅក្នុងទឹកចុះ ។ ភរិយា របស់នាយសំពៅនោះ កាលត្រូវពួកមនុស្សចាប់ប្រុងនិង បោះទៅក្នុងទឹក ត្រូវមរណភ័យគ្របសង្កត់ ក៏ស្រែកឡើង យ៉ាងខ្លាំង ។ នាយសំពៅបានឮនូវសម្រែកនោះហើយ ក៏ ពោលថា ប្រយោជន៍អ្វីដោយអាភរណៈដែលនាងប្រដាប់នោះ នឹងវិនាសទៅទទេៗ, ពួកលោកចូរដោះគ្រឿងអាភរណៈទាំង អស់ ឲ្យនាងស្លៀកសំពត់ចាស់មួយផ្ទាំង ហើយបោះនាងទៅ ក្នុងទឹកចុះ ខ្ញុំមិនអាចសម្លឹងមើលនាងដែលអណ្តែតនៅលើ ខ្នងទឹកបានទេ, ព្រោះហេតុដូច្នោះ ពួកលោកចូរយកក្អមដែល ពេញដោយដីខ្សាច់ចងក.ហើយ បោះទៅក្នុងសមុទ្ទចុះ។ ពួក មនុស្សទាំងនោះក៏បានធ្វើដូច្នោះ។ ត្រីនិងអណ្តើកប្រញាយ ស៊ីនាងក្នុងទីដែលធ្លាក់នុ៎ះឯង ។ ពួកភិក្ខុបានស្តាប់នូវរឿងនោះ ហើយ ក៏គិតថា វៀរព្រះសាស្តាចេញហើយ គ្មានអ្នកណាដឹង

នូវកម្ម របស់ស្ត្រីនោះទេ, ពួកយើងនឹងទូលសួរនូវកម្មរបស់ស្ត្រីនោះ ចំពោះព្រះសាស្តា ។ ទៅដល់ទីកន្លែងដែលប្រាថ្នាហើយ ក៏នាំ គ្នាចុះចាកសំពៅចៀសចេញទៅ ។

## ភិក្ខុ ៧ រូបអត់អាហារ ៧ ថ្ងៃក្នុងល្អាងភ្នំ

ភិក្ខុ ៧ រូប ដទៃទៀត និមន្តចេញអំពីបច្ចន្តជនបទដើម្បីនឹងមកគាល់ព្រះសាស្តាដែរ វេលាល្ងាចចូលទៅកាន់វត្តមួយ ហើយសួររកកន្លែងសំរាក ។ ក្នុងវត្តនោះមានល្អាងមួយមានគ្រែ ៧ ភិក្ខុដែលជាចៅអាវាសក៏បានប្រគល់ល្អាងនោះឲ្យភិក្ខុទាំង ៧ នោះ កាលបានល្អាងនោះហើយ ក៏នាំគ្នាដេកលើគ្រែដែលនៅក្នុងល្អាងនោះ, លុះដល់ពាក់កណ្តាលអធ្រាត ( មាន ) ផែនថ្មមួយធុំប៉ុនផ្ទះកំពូលរមៀលមកបិទទ្វារល្អាងជិត ពួកភិក្ខុ ម្ចាស់កន្លែង ពោលថា ពួកយើងបានប្រគល់ល្អាងនេះឲ្យដល់ពួកភិក្ខុអាគន្តុកៈ, ឥឡូវនេះ ស្រាប់តែមានផែនថ្មមួយផ្ទាំងធំ រមៀលមកបិទទ្វារល្អាងជិត, ពួកយើងត្រូវជួយគ្នានាំយកផែន ថ្មនោះចេញ លុះពោលដូច្នេះហើយ ក៏ឲ្យប្រជុំពួកមនុស្សទាំង ៧ ស្រុកដែលនៅជុំវិញវត្តនោះ ដើម្បីនាំយកដុំថ្មនោះចេញ សូម្បីពួកភិក្ខុនិងពួកមនុស្សទាំង ៧ ស្រុកនោះ

ខំប្រឹងព្យាយាម យ៉ាងណាក៏ដោយ ក៏មិនអាចធ្វើផែនថ្មនោះឲ្យរមៀលចេញ ទៅបាន ។

សូម្បីពួកភិក្ខុដែលនៅខាងក្នុងល្អាងនោះ ក៏ព្យាយាមដែរ ។ សូម្បីនាំគ្នាព្យាយាមយ៉ាងនេះក៏ដោយ ក៏មិនអាចរំកិលដុំថ្មនោះបានរហូត ៧ ថ្ងៃ, ពួកភិក្ខុអាគន្តុកៈត្រូវសេចក្ដីឃ្លានគ្របសង្កត់អស់ ៧ ថ្ងៃ បានវេទនាក្រៃលែងយ៉ាងធំក្នុងល្អាងនោះ ។ ក្នុងថ្ងៃទី ៧ ផែនថ្មនោះ ក៏បានរមៀលចេញឯង ពួកភិក្ខុចេញអំពីល្អាងនោះហើយ គិតថា បាបរបស់ពួកយើងនេះ វៀរលែងព្រះសាស្ដាចេញហើយ នរណាទៅហ្នឹងដឹងនូវបាបនេះ ពួកយើងនឹងទូលសួរព្រះសាស្ដា ហើយក៏នាំគ្នាចៀសចេញទៅ

## ពួកភិក្ខុទូលសួរនូវបុព្វកម្មរបស់ខ្លួននិងអ្នកដទៃ

ពួកភិក្ខុទាំងនោះ បានមកជួបពួកភិក្ខុលើកមុននៅពាក់កណ្ដាលផ្លូវ ទាំងអស់គ្នាចូលគាល់ព្រះសាស្ដា ថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរមួយ ទទួលបដិសណ្ឋារៈព្រះសាស្ដាហើយ ក៏ទូលសួរនូវហេតុដែលខ្លួនបានឃើញនិងបានសោយមកហើយដោយលំដាប់ ។ សូម្បីព្រះសាស្ដាក៏ទ្រង់ព្យាករប្រាប់ភិក្ខុទាំងនោះដោយលំដាប់យ៉ាងនេះ ( ថា )

## បុព្វកម្មរបស់ក្អែក

ម្នាលភិក្ខុទាំងឡាយ ក្អែកនោះសោយនូវកម្មដែលខ្លួនបានធ្វើហើយនោះឯង ។ ក៏ក្នុងអតីតកាល អ្នកស្រែម្នាក់ដែលមានប្រក្រតីនៅក្នុងក្រុងពារាណសី បានបង្ហាត់គោរបស់ខ្លួន ប៉ុន្តែមិនអាចបង្ហាត់បាន ។ ព្រោះថា គោរបស់គាត់នោះដើរទៅបានបន្តិចក៏ដេក, សូម្បីគាត់វាយឲ្យក្រោកឡើងហើយ ដើរទៅបានបន្តិចក៏ដេកទៀត ។ អ្នកស្រែនោះ សូម្បីព្យាយាមយ៉ាងក៏ដោយ ក៏មិនអាចបង្ហាត់គោនោះបាន ត្រូវសេចក្តីក្រោធគ្របសង្កត់ ក៏ពោលថា ឥឡូវនេះ យើងនឹងឲ្យឯងដេកជាសុខតាំងអំពីថ្ងៃនេះទៅ លុះពោលដូច្នេះហើយ ក៏ក្រងចំបើងធ្វើជាគប់មួយយ៉ាងធំហើយ យកមកចងរុំនឹងក.គោនោះហើយ ដុតភ្លើងដុត ។ គោនោះត្រូវភ្លើងឆេះក៏ស្លាប់នៅទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្អែកនោះបាននូវធ្វើបាបកម្មក្នុងកាលដែលខ្លួននៅជាកសិករនោះឯង ។ គេឆេះនៅក្នុងនរក អស់កាលដ៏យូរព្រោះបាបកម្មនោះ កើតជាកំណើតក្អែកហើយត្រូវភ្លើងឆាប់អស់ ៧ ដង ដោយអំណាច់នៃបាបកម្មដ៏សេស ។

## បុព្វកម្មរបស់ភរិយានាយសំពៅ

ម្នាលភិក្ខុទាំងឡាយ ស្ត្រីនោះ ក៏បានសោយនូវបាបកម្មដែលខ្លួនបានធ្វើហើយដែរ ។ ក្នុងអតីតកាល ស្ត្រីនោះជាភរិយានៃគហបតីម្នាក់ ដែលមានប្រក្រតីនៅក្នុងក្រុងពារាណសី បានធ្វើកិច្ចគ្រប់យ៉ាង មានដងទឹក បុកអង្ករ ចំអិនអាហារជាដើមដោយដៃរបស់ខ្លួនឯង ។ នៅក្នុងផ្ទះរបស់គហបតីនោះមានសុនខមួយ ហើយសុនខនោះតែងតែអង្គុយមើលនាងដែលធ្វើកិច្ចគ្រប់យ៉ាងនៅក្នុងផ្ទះនោះ ។ ពេលនាងនាំភត្តទៅជូនស្វាមីរបស់នាងនៅឯស្រែក្តី ពេលទៅព្រៃដើម្បីរកវត្ថុផ្សេងៗ មានឧសនិងបន្លែជាដើមក្តី សុនខនោះ តែងតែទៅតាមនាងជានិច្ច ។ ពួកបុរសកំលោះៗ ឃើញដូច្នោះ តែងតែនិយាយចំអកឲ្យនាងថា ម្នាលអ្នកទាំងឡាយ ព្រានសុនខចេញទៅព្រៃហើយវ៉ើយ, ថ្ងៃនេះ ពួកយើងនឹងបានបរិភោគបាយជាមួយនឹងសាច់ហើយ នាងក៏អៀនខ្មាសនឹងពាក្យចំអកចំអន់របស់ពួកមនុស្សទាំងនោះ ទើបប្រហារសុនខនោះដោយដុំដីនិងដំបងជាដើមឲ្យទៅវិញ ។ សុនខនោះត្រឡប់ក្រោយបានបន្តិច ក៏រត់ទៅតាមនាងវិញទៀត ។ បានឮមកថា សុនខនោះ ធ្លាប់ជាស្វាមីរបស់នាងកាលពី ៣ ជាតិមុន, ព្រោះហេតុដូច្នោះ ទើបវាមិនអាចកាត់សេចក្តីស្រឡាញ់

ដែលកើតមានចំពោះនាងបាន ពិតណាស់ បុគ្គលណាៗ ដែលឈ្មោះថា មិនធ្លាប់ជា ករិយាឬជាស្វាមីនឹងគ្នា ក្នុងសង្សារវដ្ត ដែលមាន ទីបំផុតខាង ដើមនិងខាងចុងដែលបុគ្គលតាមទៅដឹងមិនបាននោះ រមែងមិន មានឡើយ, ព្រោះហេតុដូច្នោះ សេចក្តីស្រឡាញ់ដែលមាន ប្រមាណដ៏ក្រៃលែង រមែងមានក្នុងបុគ្គលដែលជាញាតិក្នុងអត្តភាពជិតៗ, ព្រោះហេតុដូច្នោះ ទើបសុនខនោះ មិនអាចលះបង់ សេចក្តីស្រឡាញ់ដែលកើតមានចំពោះនាងនោះបាន ។ នាងក៏ក្រោធខឹងនឹងសុនខនោះ ពេលដែលនាំយកបបរទៅជូនស្វាមី ដែលនៅឯស្រែនោះ នាងបានយកខ្សែដាក់ទុកក្នុងជាយសំពត់ ហើយទើបធ្វើដំណើរទៅ ។ សុនខនោះក៏បានរត់ទៅតាមនាងដែរ លុះនាងធ្វើដំណើរទៅដល់ស្រែក៏បានយកបបរជូនស្វាមីរបស់នាង រួចហើយក៏កាន់ក្អមទទេទៅកាន់កំពង់ទឹកមួយដាក់ ខ្សាច់ឲ្យពេញក្អមនោះហើយ បានធ្វើសំឡេង ( ជាសញ្ញា ) ហៅសុនខដែលកំពុងឈរមើលនាងនៅក្នុងទីជិតនោះ ។ សុនខសប្បាយចិត្តខ្លាំងណាស់ ដោយគិតឃើញថា យូរណាស់ហើយ យើង មិនដែលបានទទួលពាក្យដ៏ពីរោះយ៉ាងនេះទេ ទើបបានទទួលតែថ្ងៃនេះឯង ,

ទើបបក់កន្ទុយដើរចូលទៅរកនាង ។ នាងចាប់កន្ទុយនោះ យ៉ាង មាំហើយ យកចុងខ្សែម្ខាងចងក្អម យកចុងខ្សែម្ខាង ទៀត ចងក.សុនខ ហើយប្រានក្អមនោះឲ្យរមៀលចុះទឹក ។ សុនខ នោះជាប់តាមក្អមធ្លាក់ទៅក្នុងទឹកងាប់នៅក្នុងទឹកនោះឯង ។ នាង នោះឆេះក្នុងនរកអស់កាលដ៏យូរ ព្រោះបាបកម្មនោះឯង ដោយ បាបកម្មដ៏សេស ទើបត្រូវគេយកក្អមពេញដោយដីខ្សាច់ចងក. ទំលាក់ចុះក្នុងទឹក ធ្វើមរណកាលក្នុងទឹកអស់ ១០០ អត្តភាព។

# បុព្វកម្មរបស់ភិក្ខុ ៧ រូប

ម្នាលភិក្ខុទាំងឡាយ សូម្បីអ្នកទាំងឡាយក៏សោយនូវ បាបកម្មដែលខ្លួនបានធ្វើហើយដូចគ្នាដែរ ។ ក្នុងអតីតកាល មានក្មេងឃ្វាលគោ ៧ នាក់ដែលមានប្រក្រតីនៅក្នុងក្រុងពា រាណសី ដើរឃ្វាលគោតាមជង្រៃព្រៃក្នុងមួយកន្លែង ៧ ថ្ងៃ ។ ថ្ងៃ មួយត្រឡប់មកអំពីឃ្វាលគោវិញ បានឃើញមេទន្សង មួយរត់ ចូលដំបូកមួយ ក៏នាំគ្នាដេញចាប់ ។ មេទន្សងនោះ ក៏រត់ ចូលទៅកាន់ដំបូកបាត់ ក៏រន្ធដំបូកនោះមានរន្ធ ៧ ។ ក្មេងៗ ទាំងនោះប្រឹក្សាគ្នាថា ថ្ងៃនេះ ពួកយើងមិនអាចចាប់វា

បានទេ ចាំថ្ងៃស្អែកពួកយើងនឹងមកចាប់វា លុះប្រឹក្សាគ្នាដូច្នេះ ហើយ ក៏នាំគ្នាកាន់យកកំណាត់ឈើបាក់ម្នាក់មួយក្ដាប់ៗ បិទ រន្ធទាំងនោះរួចហើយ ក៏ចៀសចេញទៅ ។ លុះព្រឹកឡើង ក្មេង ទាំងនោះមិនបានទឹកដល់មេទន្សងនោះ ក៏គៀងគោទៅឃ្វាល ក្នុងទីដទៃ ដល់ថ្ងៃទី ៧ គៀងគោមកវិញឃើញជំបូកនោះ ក៏ នឹកឃើញដល់មេទន្សង ក៏គិតគ្នាថា តើមេទន្សងនោះជាយ៉ាង ណាហើយហ្ន៎? បានបើករន្ធដែលខ្លួនបិទទុកនោះ ។ មេទន្សង អស់សេចក្ដីអាល័យក្នុងជីវិត សល់តែឆ្អឹង និងស្បែក ញ័រ ទទ្រើកដើរចេញមក,ក្មេងទាំងនោះឃើញដូច្នោះហើយក៏អាណិត បាននិយាយគ្នាថា ពួកយើងកុំសម្លាប់វាអី វាអត់ចំណីអស់ ៧ ថ្ងៃហើយ លុះពោលដូច្នេះហើយ ក៏អង្អែលខ្នងទន្សងនោះ ហើយក៏លែងទៅដោយពោលថា ឯងចូរធ្វើដំណើរទៅតាម សប្បាយចុះ ។ ក្មេងទាំងនោះ មិនត្រូវធេះនៅក្នុងនរក ព្រោះ មិនបានសម្លាប់ទន្សងនោះ ។ ប៉ុន្ដែជនទាំង ៧ នាក់នោះ ត្រូវ អត់បាយរួមគ្នា ៧ៗ ថ្ងៃ អស់ ១៤ អត្ដភាពមកហើយ ម្នាល ភិក្ខុទាំងឡាយ អ្នកទាំងឡាយបានធ្វើនូវបាបកម្មនោះ ក្នុងកាល ដែលអ្នកទាំងឡាយនៅជាក្មេងឃ្វាលគោ ។

ព្រះសាស្តា ទ្រង់ព្យាករបញ្ហា ដែលភិក្ខុទាំងនោះបានទូលសួរ ដោយប្រការដូច្នេះ ។

## បុគ្គលទោះនៅទីណាៗក៏ដោយក៏មិនអាចរួចចាកបាបកម្មដែលខ្លួនបានធ្វើហើយដែរ

គ្រានោះ ភិក្ខុមួយរូបបានទូលសួរព្រះសាស្តាថា បពិត្រព្រះ អង្គដ៏ចម្រើន ការរួចខ្លួនរបស់បុគ្គលដែលធ្វើនូវបាបកម្មហើយ ហោះឡើងទៅកាន់អាកាសក្តី ស្ទុះទៅកាន់សមុទ្រក្តី ចូលទៅកាន់ចន្លោះនៃភ្នំក្តី រមែងមិនមានទេឬ ? ព្រះសាស្តាទ្រង់ត្រាស់ ឆ្លើយថា “ម្នាលភិក្ខុទាំងឡាយ យ៉ាងនុ៎ះឯង” បុគ្គលឈរនៅ ក្នុងប្រទេសឯណាហើយ រួចចាកកម្មដ៏លាមក ក្នុងទីទាំងឡាយ មានអាកាសជាដើម រមែងមិនមាន, កាលនឹងទ្រង់បន្តអនុសន្ធិ ដើម្បីសំដែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

> ១១ ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
> ន បព្វតានំ វិវរំ បវិស្ស
> ន វិជ្ជតេ សោ ជគតិប្បទេសោ
> យត្រដ្ឋិតោ មុច្ចេយ្យ បាបកម្មា ។

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅ
ពួជ៏អាកាស ក្នុងកណ្ដាលសមុទ្រ កាន់ចន្លោះភ្នំ
ទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះ
ប្រទេសលើផែនដី ដែលបុគ្គលស្ថិតនៅហើយ
គប្បីរួចចាកបាបកម្មបាននោះ មិនដែលមានឡើយ ។

## អធិប្បាយគាថា

សេចក្ដីនៃព្រះគាថានោះថា ប្រសិនបើបុគ្គលណាម្នាក់ គិតថា អញនឹងរួចចាកបាបកម្មដោយឧបាយយ៉ាងនេះ ហើយ អង្គុយ ពួជ៏អាកាសក្ដី, ចូលទៅកាន់មហាសមុទ្រ ដែលមានជំរៅ ៨ ម៉ឺន ៤ ពាន់យោជន៍ក្ដី, អង្គុយក្នុងចន្លោះនៃភ្នំក្ដី, ក៏មិនអាចរួចចាក បាបកម្មបានឡើយ ព្រោះថា ប្រទេសលើផែនដី គឺភូមិភាគនៃផែនដី មានបុរត្ថិមទិសជាដើម ឱកាសសូម្បីប៉ុនចុងនៃរោមទ្រាយ ដែលបុគ្គលស្ថិតនៅហើយ គប្បីរួចចាកបាបកម្មបាន រមែងមិនមាន ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះ បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ព្រះធម្មទេសនា

*បានជាកថាមានប្រយោជន៍ដល់ជនទាំងឡាយ ដែលមកប្រជុំគ្នា នៅទីនោះឯង ។ល។*

*( រឿងជន ៣ នាក់ ចប់ )*

**************

## ១២. រឿងព្រះបាទសុប្បពុទ្ធសក្យៈ

### *សេចក្តីខាងដើម*

*ព្រះសាស្តា កាលគង់នៅក្នុងវត្តនិគ្រោធារាម ទ្រង់ប្រារព្ធព្រះបាទសុប្បពុទ្ធ ត្រាស់ព្រះធម្មទេសនានេះថា "**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**" ជាដើម ។*

### *ព្រះបាទសុប្បពុទ្ធក្រោងអន្តរាយបិទផ្លូវព្រះសាស្តា*

*បានឮថា ព្រះបាទសុប្បពុទ្ធអង្គនោះ ទ្រង់ចងអាឃាតនឹងព្រះសាស្តាដោយហេតុ ២ ប្រការ គឺព្រះសមណគោតមអង្គនេះ ចេញទៅបួសបោលធីតារបស់យើង ១ បំបួសបុត្ររបស់អញហើយ ស្ថិតនៅក្នុងឋានៈជាអ្នកមានពៀរនឹងបុត្ររបស់អញ ១, ថ្ងៃមួយ ទ្រង់ព្រះតំរិះថា យើងនឹង មិន*

ឲ្យព្រះសមណគោតមយាងទៅកាន់ទីនិមន្ត លុះទ្រង់មានព្រះតម្រិះដូច្នេះហើយ ក៏ទ្រង់គង់សោយទឹកបណ្ឌក្នុងចន្លោះផ្លូវ ដើម្បីបិទផ្លូវដែលជាទីយាងទៅកាន់ទីនិមន្តរបស់ព្រះសាស្តា ។

គ្រានោះ កាលព្រះសាស្តា ដែលមានភិក្ខុសង្ឃហែហម ស្តេចយាងមកជិតដល់ទីនោះ ពួកមហាតលិកក្រាបទូលព្រះ-រាជាថា បពិត្រមហារាជ ព្រះសាស្តា ស្តេចយាងមកហើយ ពេលនោះ ព្រះបាទសុប្បពុទ្ធ បានត្រាស់ទៅកាន់រាជបុរសថា អ្នកទាំង ឡាយ ចូរទៅប្រាប់ព្រះសមណគោតមចុះថា ព្រះសមណគោតម អង្គនេះ មិនមែនចាស់ជាងយើងទេ យើងនឹងមិនឲ្យផ្លូវដល់ព្រះ សមណគោតមអង្គនោះទេ សូម្បីពួកមហាតលិកទូលតឿន រឿយៗ យ៉ាងក៏ដោយ ក៏ទ្រង់នៅតែគង់ត្រាស់បញ្ជាយ៉ាងនោះ ដដែលៗ ។

ព្រះសាស្តា មិនបានផ្លូវអំពីសំណាក់ព្រះមាតុលៈ ( អុំ ) ទើបស្តេចយាងត្រឡប់ទៅវិញ ។ ឯព្រះបាទសុប្បពុទ្ធក៏បញ្ជូនចារបុរស ( អ្នកស៊ើបការណ៍ ) ទៅម្នាក់ ដោយព្រះតម្រាស់ថា អ្នកឯងចូរទៅស្តាប់នូវពាក្យ របស់ព្រះសមណគោតមអង្គនោះ ហើយចូរត្រឡប់មកវិញ ។

## ព្រះបាទសុប្បពុទ្ធធ្វើកម្មធ្ងន់ត្រូវផែនដីស្រូប

ចំណែកព្រះសាស្តា កាលស្តេចយាងត្រឡប់មកវិញ ទ្រង់ធ្វើនូវការញញឹមឲ្យប្រាកដ ព្រះអានន្ទត្ថេរទូលសួរថា បពិត្រ ព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាបច្ច័យនៃកម្ម គឺការញញឹម របស់ព្រះអង្គ ? ទើបទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកមាន ឃើញព្រះ បាទសុប្បពុទ្ធទេ ? ព្រះអានន្ទត្ថេរទូលថា បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ ។ ព្រះសាស្តាទ្រង់ ត្រាស់ថា ព្រះបាទសុប្បពុទ្ធនោះ មិនឲ្យផ្លូវដល់ព្រះពុទ្ធ ប្រាកដស្មើដូចជា តថាគត បានធ្វើនូវកម្មដ៏ធ្ងន់, ក្នុងថ្ងៃទី ៧ អំពីថ្ងៃនេះ ព្រះអង្គ នឹងចូលទៅកាន់ផែនដី ( ធរណីស្រូប ) ក្នុងទីជិតជើងជណ្តើរ ឰដ៏ខាងក្រោមនៃប្រាសាទ ៧ ជាន់ ។

## ព្រះបាទសុប្បពុទ្ធបំណងចាប់កំហុសព្រះសាស្តា ដោយពាក្យកុហក

ចារបុរសនោះ បានស្តាប់នូវព្រះតម្រាស់របស់ព្រះមាន ព្រះភាគហើយ ទៅកាន់សម្នាក់ព្រះបាទសុប្បពុទ្ធៗ ត្រាស់សួរថា ក្មួយរបស់យើងត្រឡប់ទៅវិញ បាននិយាយនូវពាក្យអ្វីខ្លះ ?

ទើបក្រាបទូលតាម ដែលខ្ញុំបានឮ ។

ព្រះបាទសុប្បពុទ្ធទ្រង់ព្រះសណ្ដាប់នូវពាក្យដែលចារបុរសនោះបានក្រាបទូលហើយ ទ្រង់ត្រាស់ថា ឥឡូវនេះ ទោសក្នុងការនិយាយ ( កុហក ) នៃក្មួយរបស់យើង រមែងមិនមាន, ព្រះអង្គត្រាស់នូវពាក្យណា ពាក្យនោះរមែងមានដោយប្រការដូច្នោះមែន ប៉ុន្តែសូម្បីដូច្នោះក៏ដោយ ពេលនេះ យើងនឹងផ្ចញ់ផ្ចាល់ព្រះអង្គដោយការនិយាយកុហក, ព្រោះព្រះអង្គមិនបានត្រាស់នឹងយើង ដោយប្រាកដថា ព្រះបាទសុប្បពុទ្ធនឹងត្រូវធរណីស្រូបក្នុងថ្ងៃទី ៧, គ្រាន់តែត្រាស់ថា សុប្បពុទ្ធនឹងត្រូវធរណីស្រូបក្នុងទីជិតជើងជណ្ដើរ ខាងក្រោមប្រាសាទប៉ុណ្ណោះ បើដូច្នោះ តាំងអំពីថ្ងៃនេះទៅ យើងនឹងមិនទៅកាន់ទីនោះ កាលបើដូច្នោះ យើងមិនត្រូវធរណីស្រូបក្នុងទីនោះឡើយ នឹងសង្កត់សង្កិន ក្មួយរបស់យើងដោយការនិយាយកុហក ។

## ព្រះបាទសុប្បពុទ្ធទ្រង់ធ្វើការរក្សាព្រះអង្គយ៉ាងម៉ឺងម៉ាត់

ព្រះបាទសុប្បពុទ្ធបញ្ជាឲ្យពួកមហាតលិក ជញ្ជូនវត្ថុទាំងពួង ដែលជាគ្រឿងឧបភោគរបស់ព្រះអង្គទៅទុកលើប្រាសាទ

៧ ជាន់ បញ្ជាឲ្យដកជណ្ដើរចេញ ឲ្យបិទទ្វារ ដាក់មនុស្ស មាឌមាំៗ ពីរនាក់ត្រង់ទ្វារមួយៗ ហើយត្រាស់ថា ប្រសិនបើពួកឯងឃើញយើងដើរចុះទៅខាងក្រោម ដោយការប្រមាទសោត, អ្នកទាំងឡាយគប្បីហាមឃាត់យើង លុះពោលដូច្នេះហើយ ក៏ទ្រង់គង់ ក្នុងបន្ទប់ដ៏មានសិរីលើផ្ទៃប្រាសាទជាន់ទី ៧ ។

## នឹងគេចអំពីផលនៃកម្មអាក្រក់មិនផុតឡើយ

ព្រះសាស្ដា ទ្រង់ព្រះសណ្ដាប់នូវរឿងនោះហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រះបាទសុប្បពុទ្ធនេះ កុំថាឡើយតែគង់នៅលើផ្ទៃប្រាសាទរហូតនោះ, ទោះបីហោះឡើងទៅកាន់វេហាស៍ហើយ អង្គុយក្នុងអាកាសក៏ដោយ, ចូលទៅកាន់មហាសមុទ្រដោយសំពៅក៏ដោយ, ចូលទៅកាន់ចន្លោះភ្នំក៏ដោយ, ដែលឈ្មោះថាការៈនៃព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយ រមែងមិនមានពីរ, ព្រះអង្គនឹងត្រូវធរណី ស្រូបក្នុងទីដែលតថាគតពោលហើយនោះឯង កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

**១២ ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**

ន បព្វតានំ វិវរំ បវិស្ស
ន វិជ្ជតេ សោ ជគតិប្បទេសោ
យត្រដ្ឋិតំ នប្បសហេយ្យ មច្ចុ ។

បុគ្គលទៅឰដ៏អាកាស ក្នុងកណ្ដាលសមុទ្ទ កាន់ចន្លោះនៃភ្នំទាំងឡាយ ក៏មិនរួចចាកសេចក្ដីស្លាប់បាន ព្រោះប្រទេសលើផែនដី ដែលបុគ្គលស្ថិតនៅហើយ សេចក្ដីស្លាប់គ្របសង្កត់មិនបាននោះ មិនមានឡើយ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ ពីរបទថា **នប្បសហេយ្យ មច្ចុ** ក៏ប្រទេស គឺផែនដី សូម្បីត្រឹមតែប៉ុនចុងសក់ ដែលមរណៈមិនគប្បីញាំញី គឺមិនគប្បីគ្របសង្កត់អ្នកដែលស្ថិតនៅទីនោះរមែងមិនមាន, ពាក្យដ៏សេស ក៏ដូចគ្នានឹងពាក្យមុននោះឯង ។

ក្នុងកាលចប់ទេសនា ជនជាច្រើន បានសម្រេចអរិយ-ផល ទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

## សេះមង្គលជាហេតុឲ្យព្រះបាទសុប្បពុទ្ធ ចុះចាកប្រាសាទ

លុះដល់ថ្ងៃទី ៧ ក្នុងវេលាដូចវេលាដែលព្រះបាទសុប្បពុទ្ធ បិទផ្លូវភិក្ខាចាររបស់ព្រះសាស្តា សេះមង្គលរបស់ព្រះអង្គដែលនៅខាងក្រោមប្រាសាទ លោតកញ្ជ្រោលឡើងផាយជាក់ជញ្ជាំងនោះៗ ។

ព្រះអង្គប្រថាប់គង់នៅជាន់លើនោះឯង បានឮសំឡេងសេះនោះ ក៏ត្រាស់សួរថា នុ៎ះជាសំឡេងអ្វី ? ពួកមហាតលិកទូលថា សេះមង្គលលោតកញ្ជ្រោល ។ ចំណែកសេះនោះគ្រាន់តែ ឃើញព្រះបាទសុប្បពុទ្ធភ្លាម ក៏ឈប់ស្ងៀម ។

## កើតហេតុគួរឲ្យចម្លែកព្រោះកម្មអាក្រក់

ខណៈនោះ ព្រះអង្គមានបំណងនឹងចាប់សេះនោះ បានស្តេចក្រោកចាកទីប្រថាប់ បែរព្រះភក្ត្រមករកទ្វារ ។ ទ្វារទាំង-ឡាយបើកឯង, ជណ្តើរតាំងនៅក្នុងទីរបស់ខ្លួនដូចដើម ។ ទ្វារប្រាសាទទាំង ៧ ក៏បើកឯង, ជណ្តើរទាំងឡាយក៏តាំងនៅក្នុងទី ដើម ។ ពួកមនុស្សដែលខ្លាំងៗ ( នៅប្រចាំ ) ត្រង់ជាន់នោះៗ ចាប់ព្រះបាទសុប្បពុទ្ធត្រង់ព្រះសូរងហើយប្រានឲ្យមាន ព្រះភក្ត្រចុះមកខាងក្រោម ។

## ព្រះអង្គត្រូវផែនដីស្រូបទៅកើតក្នុងអវីចីនរក

ខណៈនោះ មហាប្រថពីហែកញែករង់ចាំទទួលព្រះបាទសុប្បពុទ្ធនៅជិតជើងជណ្តើរ ខាងក្រោមប្រាសាទនោះឯង, ព្រះអង្គលិចចូលទៅក្នុងផែនដី ហើយក៏កើតក្នុងអវីចីនរក ។៚

( រឿងព្រះបាទសុប្បពុទ្ធសក្យៈ ចប់ )

****************

បាបវគ្គវណ្ណនា ចប់

វគ្គទី ៩ ចប់

*****